## សម្ភាសន៍ជាមួយ វ៉ាន់ ស៊ានលី ភេទស្រី អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ឆ្មប

## សព្វថ្ងៃរស់នៅភូមិធំ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី និង រី លក្ខិណា

## ០១:០៧:៥២

## ៣០ទំព័រ

ធានី : ជំរាបសួរមីង! ខ្ញុំឈ្មោះ ធានី គាត់ឈ្មោះ លក្ខិណា ទាំងពីរនាក់មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយខ្ញុំសុំអនុញ្ញាតិ មីង ថតជាសំលេង ហើយថតជារូបភាពបានទេមីង?

ស៊ានលី : ចាស៎

ធានី : ពួកខ្ញុំសម្ភាស មីង ទាក់ទងប្រវត្តិ មីង នៅសម័យខ្មែរក្រហម ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានរៀនបានសូត្រថាសម័យនោះម៉េចៗណា៎មីង? មីងឈ្មោះអីដែរ?

ស៊ានលី : ខ្ញុំឈ្មោះ វ៉ាន់ ស៊ានលី ។

ធានី : អាយុប៉ុន្មានហើយ មីង?

ស៊ានលី : ខ្ញុំអាយុ ៥៥ ។

ធានី : មីង មានស្រុកកំណើតនៅកន្លែងណាដែរ?

ស៊ានលី : នៅទីងតែម្តង ភូមិធំ ឃុំកំពែង ទីងតែម្តង ។

ធានី : ស្រុកអីគេដែរ?

ស៊ានលី : ស្រុកគិរីវង់ ខេត្តតាកែវ ។

ធានី : អញ្ចឹង! មីង រៀបការហើយឬក៏នៅ?

ស៊ានលី : ខ្ញុំហើយ ។

ធានី : រៀបនៅពេលណាដែរ?

ស៊ានលី : ជំនាន់ ប៉ុល ពត ។

ធានី : គាត់ឈ្មោះអីដែរ មីង?

ស៊ានលី : ឈ្មោះ ពូប៉ាក់

ធានី : ឈ្មោះ ពូប៉ាក់ អញ្ចឹងតែម្តង?

សំានលី ៖ ចាស៎!

ធានី ៖ ត្រកូលគាត់?

សំានលី ៖ ត្រកូលមិនដឹងស្អីទេ!

ធានី ៖ ចុះមីង មានកូនប៉ុន្មាននាក់ដែរ?

សំានលី ៖ ខ្ញុំអត់មានកូន។

ធានី ៖ ចុះឪពុកមីង ឈ្មោះអី?

សំានលី ៖ ឪពុកខ្ញុំឈ្មោះ វ៉ាន់ ហ៊ួ។

ធានី ៖ គាត់នៅរស់ទេ?

សំានលី ៖ អត់ទេ! គាត់ស្លាប់បាត់ គាត់ដាច់បាយ គាត់ហើម។

ធានី ៖ ចុះម្ដាយ មីង?

សំានលី ៖ ម្ដាយខ្ញុំឈ្មោះ កេះ នួន។

ធានី ៖ គាត់នៅរស់ទេ មីង?

សំានលី ៖ ស្លាប់បាត់ហើយ។

ធានី ៖ ស្លាប់ពេលណាដែរ?

សំានលី ៖ ស្លាប់នៅជំនាន់ ប៉ុល ពត ដែរ។ គាត់កើតលឿង ហើយគេឲ្យទៅចូកស្មៅក្រុម ហើយគាត់ល្ងប់ស្លាប់។

ធានី ៖ អញ្ចឹងមីង ធ្លាប់បានទៅរៀនសូត្រនៅរដ្ឋទេ មុនសម័យខ្មែរក្រហម?

សំានលី ៖ ទៅរៀននៅសាលា?

ធានី ៖ ចាស៎!

សំានលី ៖ ខ្ញុំទៅ។

ធានី ៖ រៀនថ្នាក់ទីប៉ុន្មាន?

សំានលី ៖ ទី៩ ពីដើម។

ធានី ៖ ចុះម៉េច! បានមីងឈប់រៀន?

សំានលី ៖ ចុះរដ្ឋប្រហារនោះ! រដ្ឋប្រហារទម្លាក់សម្ដេច មិនរប៉ាត់រប៉ាយអស់។

ធានី ៖ ឆ្នាំប៉ុន្មាន មីងចាំទេ?

សំានលី ៖ រដ្ឋប្រហារនឹងមិនឆ្នាំប៉ុន្មានទេ វាទម្លាក់សម្ដេចនឹង។

ធានី ៖ ហើយម៉េចទៀតទៅមីង?

ស៊ានលី ៖ ដល់ហើយ វារបៀត់របៀយរត់បែកគ្នា បានសាលាណារៀនទៀត? គ្មានសាលារៀនណា?

ធានី ៖ ពេលនឹង មីងទៅណាទៅ?

ស៊ានលី ៖ ខ្ញុំរត់ទៅស្រុកលើ កំពង់ធំ កំពង់ស្ពឺ អញ្ចឹងទៅ!

ធានី ៖ ទៅកំពង់ស្ពឺធ្វើអីមីង?

ស៊ានលី ៖ រត់ទៅសុំគេនៅ ហើយដល់នេះមកបានបែកគ្នាមកស្រុកយើងវិញ ។

ធានី ៖ អញ្ចឹង! ខ្ញុំសុំឲ្យមីង ជួយរៀបរាប់ប្រវត្តិរបស់មីង នៅសម័យ ប៉ុល ពត តើមីងបានឆ្លងកាត់អីខ្លះ ហើយបានជួបហេតុការណ៍អីខ្លះ មុននឹងមីងចាប់ផ្ដើមធ្វើពេទ្យឬមុនពេលចេញធ្វើពេទ្យ រហូតហេតុអីបានធ្វើពេទ? បន្ទាប់មកទៀត ជួបរឿងអីខ្លះ? បានជួបអ្នកណាគេ? មានរឿងអីខ្លះ?

ស៊ានលី ៖ ខ្ញុំមុននឹងបានធ្វើពេទ្យនឹងវេទនាណាស់ ។ គេឲ្យទៅស្រុកដីរមៀល ហើយខ្ញុំនៅតូចៗអើយ! ខ្ញុំមិនធាត់អញ្ចឹងទេ ស្ដើង ។ ហើយគេថា យើងធ្លាប់នៅនេះ មានហូបមានពេល ។ ហើយនៅអត់បាន រត់ចុះមកវិញ ។ ហើយនៅនឹងចេះធ្វើការងារនឹងគេ ដាំដំឡូងដាំអីអញ្ចឹងទៅដល់ហើយយូរៗទៅ ខ្ញុំដំបៅជើង បានគេឲ្យទៅដេកពេទ្យ ។ ដេកពេទ្យបីខែ ដល់ហើយពេទ្យ គេខ្វិល ហើយខ្ញុំឃើញអញ្ចឹងខ្ញុំចង់ ខ្ញុំក៏ដើរទៅចាក់ថ្នាំលាងរបួស ហើយយើងធ្វើកើតបាន គេឲ្យយើងចូលពេទ្យនឹង ។

ធានី ៖ អញ្ចឹងមីង ទៅដីរមៀលនៅសឆ្នាំណា?

ស៊ានលី ៖ ខ្ញុំអត់ដឹងឆ្នាំ ពេលនឹងខ្មែរក្រហមនឹង ។ ហើយចេះបាននៅបានអូន ចេះស្លចេកម៉ាខ្វែក នៅតែពីរស្និទ្ធទេ ហើយមិនដឹងម្ហូបអីណា ញ៉ាំវាមិនកើតបានចង់រត់មកវិញ ។

ធានី ៖ មីងមានចាំទេ កាលនឹងម៉េចបានមីងទៅដល់ដីរមៀលនឹង?

ស៊ានលី ៖ គេថាគេយកយើងទៅពង្រឹកគោលជំហរចូលនារីក្លាហានវៃទ័ព ។ ចូលកងនារី យើងតស៊ូបានគេឲ្យយើងចូលកងនារីទៅវៃយួនវៃអីដែរនឹង ។ ហើយវានៅមិនបាន ។

ធានី ៖ ដល់ពេលមីងចូលកងនារីនឹង គេមានប្រជាជនថ្មីនៅក្នុងភូមិមីងនៅ?

ស៊ានលី ៖ ប្រជាជនយើងនឹង មិនប្រជាជនថ្មី?

ធានី ៖ អត់មានប្រជាជនថ្មីមកពីណាមីង?

ស៊ានលី ៖ អត់!

ធានី ៖ ពេលទៅនឹង បានប៉ុន្មានខែបានមីងរត់មកវិញ?

ស៊ានលី ៖ ទៅបានជិត២ខែដែរ នៅមិនបាន ។ វាធ្វើឲ្យយើងហូបមិនកើត គ្មានកម្លាំង ។

ធានី ៖ ពេលដែលមីងទៅដល់នឹង អ្នកណាគេអ្នកនាំមីងទៅ?

ស៊ានលី ៖ គេអ្នកមេយើង មេដឹកនាំពីនឹងទៅ ។

ធានី ៖ ឈ្មោះគាត់អី?

ស៊ានលី ៖ ឈ្មោះគាត់ ខ្ញុំអត់ចាំទេ មិនដឹងឈ្មោះអីៗទេ វាយូរមកហើយ ។

ធានី ៖ អ្នកស្រុកយើងឬមកពីណាមកវិញ?

ស៊ានលី ៖ អ្នកស្រុកគេ ក្នុងស្រុក១០៥ ។

ធានី ៖ ហើយអត់ចាំឈ្មោះគាត់ទេ?

ស៊ានលី ៖ អត់ចាំឈ្មោះទេ ភ្លេច ។

ធានី ៖ ហើយគាត់យកតែមីងម្នាក់ឯងទេ?

ស៊ានលី ៖ អត់ទេ! ទៅច្រើនគ្នា ។

ធានី ៖ ប៉ុន្មាននាក់ដែរ មីង?

ស៊ានលី ៖ ទៅប្រហែល៥០នាក់ ច្រើនដែរ ។ ដេញវាងយើងមិនឲ្យយើងចុះមកវិញ គេនាំយើងវាងទៅណាទៅណី ទំរាំដល់ភ្នំនឹងប៉ុន្មានយប់ ។ ពេលយើងរត់ចុះមកវិញ ដេកតែមួយយប់ដល់ស្រុកយើង ។

ធានី ៖ ហើយរត់មកវិញតែម្នាក់ឯង?

ស៊ានលី ៖ អត់ទេ! រត់មកច្រើនគ្នាដែរ មិនមែនមកម្នាក់ឯងហ៊ានមកទេ ។

ធានី ៖ ប៉ុន្មាននាក់ទៅ?

ស៊ានលី ៖ មកប្រហែល ២០នាក់ជាង ។ អានាក់គេស៊ូគេនៅ អានាក់ស៊ូអត់បានគេមកវិញ ។ ហើយដល់ពេលមកវិញ គេថានារីបាក់ទ័ព ។ ថានារីបាក់ទ័ពក៏ថាចុះ ព្រោះអីនៅមិនបាន ។

ធានី ៖ ខាងណាគេ អ្នកថាអញ្ចឹង?

ស៊ានលី ៖ ខាងគេនឹង គេដឹកនាំយើងទៅនឹង ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ?

ស៊ានលី ៖ អត់ស្គាល់ទេ! ខ្ញុំមិនបានស្គាល់ឈ្មោះ ។

ធានី ៖ គាត់អញ្ចឹងគេមកតាមហៅវិញ ។

ស៊ានលី ៖ គេមកតាមវិញ ដឹងថាយើងមកដល់ស្រុកគីរីវង់វិញហើយ ។

ធានី ៖ មកតាមមីងធ្វើអីដែរ?

ស៊ានលី ៖ គេអត់តាមហៅទៅទេ គ្រាន់តែតាមថាយើងមកដល់ស្រុកយើងវិញហើយ ។

ធានី ៖ មីងពេលគេតាមមីងអញ្ចឹង គេមានធ្វើអីមីងអត់?

ស៊ានលី ៖ គេអត់មានធ្វើអីទេ ។ ដូចពេលខ្ញុំនិយាយអញ្ចឹងថា នៅយូរៗទៅ ខ្ញុំដំបៅជើងនឹង បានទៅពេទ្យ បានគេឲ្យយើងចូលពេទ្យ ។

ធានី ៖ ខាងណាអ្នកឲ្យមីងចូលពេទ្យ?

ស៊ានលី ៖ ខាង ប៉ុល ពត នឹងអូន ។

ធានី ៖ ស្គាល់ឈ្មោះគាត់?

ស៊ានលី ៖ ប៉ុល ពត ប្រធានគេឈ្មោះ មីងឃឿន ។ មីងឃឿន នឹងនៅស្រុក១០៥ដែរ ។

ធានី ៖ មិញមីងថា មីងឃឿននឹងមកពីស្រុក១០៥ គាត់ជាអ្នកហៅមីងឲ្យចូលធ្វើពេទ្យនឹង?

ស៊ានលី ៖ ចាស៎! គាត់នឹងគណៈស្រុកស្រី ។

ធានី ៖ គេហៅស្អីគេ?

ស៊ានលី ៖ មិនដឹងហៅម៉េច ហៅ បងឃឿន នឹង គណៈស្រុកអញ្ចឹងតែម្តង គេអ្នកធំដែរ ។

ធានី ៖ គណៈស្រុកនៅណាវិញមីង?

ស៊ានលី ៖ គណៈស្រុកនឹង កាលនឹងនៅខាងកើតនេះ គេធ្វើគណៈស្រុកនៅឃុំខាងកើតនឹង ។

ធានី ៖ ហើយគាត់ជាគណៈស្រុកនឹង គាត់ជាគណៈស្រុកអីគេ? ព្រោះមីងនិយាយមិញនឹងគាត់មកពីស្រុក១០៥ ។

ស៊ានលី ៖ ចាស៎! គាត់នៅស្រុក១០៥ តែគេផ្លាស់ពី១០៥ មកនៅគីរីវង់យើងធ្វើគណៈស្រុកអញ្ចឹងតែម្តង តែមិនដឹងគណៈស្រុកខាងស្អី ត្រួតត្រាខាងនារីយើងទៅណាស់ ។

ធានី ៖ ហូ! គាត់ត្រួតត្រាខាងនារី?

ស៊ានលី ៖ ចាស៎!

ធានី ៖ ហើយគណៈស្រុកនឹងលេខប៉ុន្មានដែរ?

ស៊ានលី ៖ គណៈស្រុកនឹង ដឹងតែគណៈស្រុកមួយគេនឹង បងឃឿននឹងតែម្តង ហើយអត់ដឹងណា ។

ធានី ៖ ហើយគាត់គ្រប់គ្រងខាងនារី?

ស៊ានលី ៖ គាត់ខាងនារី ។

ធានី ៖ គ្រប់គ្រងអីគេទៅ?

ស៊ានលី ៖ គ្រប់គ្រងថាមើលការខុសត្រូវយើងធ្វើអីៗអញ្ចឹងអូន ធ្វើការងារអី ធ្វើពេទ្យធ្វើអី ដូចថាធ្វើ កងនារីកងអីគេគ្រប់គ្រងអញ្ចឹង ។

ធានី ៖ គាត់គ្រប់គ្រងទាំងអស់មីង?

សារ៉ានលី ៖ ចាស៎!

ធានី ៖ ចុះពេលដែលមីងចូល គេឲ្យមីងទៅកន្លែងណា?

សារ៉ានលី ៖ ពេលដែលខ្ញុំចូលនឹង ខ្ញុំនៅគោកគ្រួស នៅឃុំកំព្រិច ។

ធានី ៖ ហើយឲ្យមីងទៅនៅកន្លែងនឹង?

សារ៉ានលី ៖ គេឲ្យខ្ញុំនៅគោកគ្រួសនឹងតែម្តង ។

ធានី ៖ ធ្វើស្អីគេមីង?

សារ៉ានលី ៖ ពេទ្យ!

ធានី ៖ ពេទ្យនឹងនៅឃុំគោកគ្រួស តែម្តង?

សារ៉ានលី ៖ ចាស៎! នៅឃុំគោកគេ គេធ្វើមន្ទីរពេទ្យដូចសាលារៀន វែង ២ ៣កន្លែង នៅក្នុងព្រៃគ្មាន នៅកណ្តាលភូមិអញ្ចែងទេ នៅកណ្តាលព្រៃតែម្តង ។

ធានី ៖ ហើយមីងទៅនៅកណ្តាលព្រៃនឹង?

សារ៉ានលី ៖ គេធ្វើមន្ទីរពេទ្យនៅកណ្តាលព្រៃអញ្ចឹង ។

ធានី ៖ មីងមានដឹងថាមូលហេតុអីបានគេធ្វើមន្ទីរនៅកណ្តាលព្រៃ?

សារ៉ានលី ៖ មិនដឹងដែរ គេហៅឲ្យទៅ ។ ទៅដល់ឃើញនៅកណ្តាលព្រៃអញ្ចឹង ។

ធានី ៖ ពេលមីងទៅដល់ ដំបូងគេឲ្យមីងធ្វើអីគេ?

សារ៉ានលី ៖ ដំបូងដូចខ្ញុំប្រាប់អញ្ចឹង ខ្ញុំដំបៅជើង គេពេទ្យដូចអូនឯងអញ្ចឹង គេធ្លាប់ចេះហើយគេខ្ជិល ។ អញ្ចឹង! ខ្ញុំមើលឃើញអញ្ចឹង ខ្ញុំចង់! អញ្ចឹង! ខ្ញុំលាងរបួសចាក់ថ្នាំអីទៅ ។ គេដឹងថាយើងចេះធ្វើបានកើតដែរ គេក៏ឲ្យយើងចូលធ្វើពេទ្យទៅ ។

ធានី ៖ ឲ្យចូលធ្វើតែម្តង? អត់មានប្រាប់អីទេ?

សារ៉ានលី ៖ យើងមើលគេ មានគេបង្រៀនយើង ដូចថាគេចាក់ថ្នាំនឹងបំបាត់ក្តៅអញ្ចឹង ឈ្មោះអីយើងមើលថ្នាំ បិទផ្លាកមិនសរសេរ បារាំង អង់គ្លេស អីទេ! គេសរសេរខ្មែរបិទផ្លាកលើដបនឹងតែម្តង ដូចថាគ្រុនយើងចាក់ថ្នាំគ្រុន ក្តៅយើងចាក់ថ្នាំក្តៅ ។

ធានី ៖ មីងអាចអានអក្សរបាន អញ្ចឹងមីងដឹងច្រើនថាថ្នាំណាអាចប្រើអីបាន ។ អញ្ចឹង!មីងម៉េចដឹងថាថ្នាំណាសម្រាប់គ្រុន ។ មីងដឹងថាអ្នកនឹងគ្រុនហើយ មីងម៉េចដឹងថាអ្នកនឹងគ្រុន?

សារ៉ានលី ៖ ដូចថាគេឈឺក្តៅអញ្ចឹង យើងដឹងថាគេគ្រុនហើយ ។

ធានី ៖ អញ្ចឹង! ពេទ្យនឹងអត់មានប្រាប់ថាអាការៈម៉េចគ្រុន?

សារ៉ានលី ៖ ពេទ្យនឹងគេអញ្ចែងអូន! ដូចថាដំបូងម៉ាថ្ងៃពីរថ្ងៃគេប្រាប់យើង ។

ធានី ៖ ប្រាប់ថាម៉េចខ្លះមីង?

ស៊ានលី ៖ ប្រាប់ថា ចាក់អានេះៗត្រូវជម្ងឺ អានេះត្រូវជម្ងឺនេះ ។ អញ្ចឹង! យើងចាំចំណាំទុក ។

ធានី ៖ គេប្រាប់ប៉ុន្មានថ្ងៃមីង?

ស៊ានលី ៖ គេប្រាប់បីបួនថ្ងៃអញ្ចឹង ដល់យើងមន្ទិលសង្ស័យយកថ្នាំទៅសួរគេ ទៅសួរទៅខ្លាចងាប់គេដែរ ។

ធានី ៖ ដល់គេប្រាប់នឹងប្រាប់ថាម៉េចខ្លះរឿងថ្នាំរឿងអីមីង ។

ស៊ានលី ៖ គេប្រាប់ថាអានេះត្រូវជម្ងឺក្តៅ អានេះត្រូវថ្នាំកម្លាំងអញ្ចឹងអូន ហើយអានេះត្រូវថ្នាំគ្រុនអីអញ្ចឹងទៅ ។

ធានី ៖ ចុះដូចរៀបព្យាបាលអីមានប្រាប់មីងទេ?

ស៊ានលី ៖ ព្យាបាលគេប្រាប់ថា ថ្នាំនេះត្រូវលេបផងចាក់ផង ។

ធានី ៖ គេប្រាប់យើង?

ស៊ានលី ៖ គេប្រាប់ថា ថ្នាំគ្រុនថាចាក់ហើយឲ្យលេបផង ថ្នាំក្តៅថ្នាំរាគអីអញ្ចឹង ។

ធានី ៖ តែមីងដូចថា ជាធម្មតាយើងចេះចាក់ដែរប៉ុន្តែយើងអត់ដឹងថាកន្លែងណាត្រូវចាក់កន្លែងណា តែគេមានប្រាប់បង្រៀនយើង?

ស៊ានលី ៖ គេប្រាប់តើអូន ។

ធានី ៖ គេប្រាប់ថាម៉េច?

ស៊ានលី ៖ គេប្រាប់យើងអាណាចាក់សរសៃៗអាណាចាក់សាច់ដុំៗ ។

ធានី ៖ គេមានបង្រៀនមីងពីរបៀបរបៀបអី ដូចថាចាក់សរសៃចាក់ម៉េច ចាក់សាច់ចាក់ម៉េច?

ស៊ានលី ៖ គេហៅហៅយើងទៅមើលដូចថា អូនឯងត្រូវឈឺអីត្រូវចាក់ថ្នាំសរសៃ គេយកអានឹងមក ហើយគេចងដៃចងអីប្រាប់សរសៃឡើងចាក់ ហើយគេធ្វើឲ្យយើងមើល ដល់ពេលហើយយើងមើលគេអញ្ចឹងទៅណាស់ ។

ធានី ៖ បន្ទាប់មកទៀត ម៉េចមីងធ្វើនៅពេទ្យនៅក្នុងព្រៃនឹង? នៅក្នុងព្រៃនឹងនៅរហូតឬក៏ម៉េច?

ស៊ានលី ៖ គេនៅក្នុងព្រៃនឹង ដល់ហើយឃើញមានមេគេមកពីណាអញ្ចឹងគេមកត្រួតពិនិត្យអញ្ចឹងទៀតទៅ ។

ធានី ៖ មេមកពីខាងណា?

ស៊ានលី ៖ មេគេនឹងមិនដឹងមកខាងណាអូន! យើងតូចតាចអញ្ចឹងមិនអាចសួរគេបានទេ មិនហ៊ានទេ ។ ថ្នាក់ៗគេអញ្ចឹង តូចចេះដឹងរឿងអាធំគេវ៉ៃចោលទៀត ។

ធានី : ម៉េចអញ្ចឹងមីង?

ស៊ានលី : មិនដឹងទេអូនអើយ! ខ្លាចចង់ងាប់ហើយ ។

ធានី : បន្ទាប់ពីមានគេមកមើលអីអញ្ចឹង មីងមានអីទៀតទេ? មីងនៅក្នុងមន្ទីររហូត?

ស៊ានលី : គេមកលេងអីអញ្ចឹង ដូចថាយើង គេមិនឲ្យយើងដឹងការងារទេ គេដេញយើងឲ្យចេញអញ្ចឹង ។

ធានី : បន្ទាប់មកទៀតម៉េចទៀត?

ស៊ានលី : បន្ទាប់មកទៀត គេពិភាក្សាគ្នាហើយគេក៏ទៅៗ មិនយើងចូលទៅមើលអ្នកជម្ងឺយើងវិញ

ធានី : ហើយអ្នកជម្ងឺនឹងមកពីណាវិញមីង?

ស៊ានលី : អ្នកជម្ងឺនឹងដូចថាកងទ័ព ប្រជាជនអីអញ្ចឹងដែរ

ធានី : ទាំងអស់នៅក្នុងព្រៃទេ?

ស៊ានលី : ចាស៎! នៅក្នុងព្រៃជំនាន់នឹង ។ នៅក្នុងព្រៃទំរាំចេញនឹងរួច បានចូលទៅដល់សាលាគិរីវង់ សាលាបង្រៀនអានឹងពេទ្យស្រុកហើយ ។

ធានី : កាលសម័យនឹងមីង?

ស៊ានលី : ចាស៎!

ធានី : ន្លែងសាលារៀនយើងសព្វថ្ងៃនឹង?

ស៊ានលី : ចាស៎! កន្លែងរៀននឹង អានឹងពេទ្យគេ ។

ធានី : ពេទ្យស្រុកយើងកាលសម័យនឹង?

ស៊ានលី : ចាស៎! ហើយទំរាំបានចេញពីព្រៃនឹងរាប់ឆ្នាំ ។

ធានី : ប៉ុន្មានឆ្នាំមីង?

ស៊ានលី : ចុះបើ ៧២ឆ្នាំដែរ អាពតបានតែ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ វា២ឆ្នាំជាងតិចតួចបានចេញទៅនឹងបែកគ្នា ។

ធានី : អញ្ចឹងមីងទៅនៅស្រុកគិរីវង់នឹង បានប៉ុន្មានថ្ងៃ?

ស៊ានលី : ខ្ញុំនៅនឹងប្រហែលបានម៉ាឆ្នាំបែកគ្នាទៅ ។

ធានី : បែកគ្នាទៅណាវិញមីង?

ស៊ានលី : បែកទៅ! អាខ្លះរត់ប៉ោត់រប៉ាយបែកបាត់គ្នាអស់អញ្ចឹង ។ គ្មានមេគ្មានកើយ ដើរព្រៃបាត់អស់ ។

ធានី : ហេតុអីបានគេ ដូចថាដំបូងយើងនៅពេទ្យក្នុងព្រៃ ម៉េចបានគេដូរមកនៅសាលារៀន?

សំានលី ៖ មិនដឹងម៉េចគេនាំយើងឲ្យទៅនៅនឹង ឲ្យនៅក្នុងព្រៃអញ្ចឹង ។

ធានី ៖ អ្នកណាគេអ្នកនាំ?

សំានលី ៖ មេប្រធានយើងនឹង?

ធានី ៖ ឈ្មោះអី?

សំានលី ៖ ប្រធានពេទ្យនឹងឈ្មោះ យាយរឿន ប្រធានឆ្មប ។ យាយរឿននឹងក៏នៅស្រុកលើដែរ ។

ធានី ៖ នៅស្រុកណាមីង?

សំានលី ៖ នៅស្រុក ១០៥ ។

ធានី ៖ អញ្ចឹង!មីងប្រាប់ខ្ញុំថារៀនចាក់ថ្នាំចាក់អី អញ្ចឹងពេលណាបានមីងរៀនពេទ្យឆ្មប? រៀនធ្វើឆ្មបធ្វើអី?

សំានលី ៖ ពេទ្យឆ្មបនឹង យើងគេហៅចាក់ថ្នាំសាស្ត្រអីឲ្យអញ្ចឹងទៅឲ្យគេលេបថ្នាំសាស្ត្រអីឲ្យអញ្ចឹងទៅ ។ ថ្នាំគេស្លហើយ គេលាយជាមួយមេ្សៅ ហើយគេមានអាពុម្ពគេអុសអញ្ចឹងគេអាលាក់ គេហាលថ្ងៃឲ្យរីងអញ្ចឹង ។

ធានី ៖ ម៉េចបានឃើញ?

សំានលី ៖ ខ្ញុំឃើញដែរ គេស្លនៅនឹង ។

ធានី ៖ តែមីងមានចូលរួមស្លនឹងគេទេ?

សំានលី ៖ អត់ទេ! ខ្ញុំអត់ដឹង ។

ធានី ៖ គ្រាន់តែបានឃើញគេចាក់ពុម្ពហាលថ្ងៃ? អញ្ចឹង! ពេលដែលមីងបានឃើញមីងនៅណា?

សំានលី ៖ ខ្ញុំនៅគោកគ្រួស ។

ធានី ៖ ពេលដែលមីងទៅដល់ពេទ្យថ្មី?

សំានលី ៖ ទៅដល់នឹង គេឈប់ធ្វើអានឹងហើយ អាកន្លែងធ្វើថ្នាំនឹងនៅផ្សេង អាកន្លែងកើតកូននៅផ្សេងដែរ ។

ធានី ៖ នៅណាវិញ?

សំានលី ៖ នៅគីរីវង់ ដែលប្រាប់សាលារៀនមិញនឹង ។

ធានី ៖ ទៅតែមីងម្នាក់ឯងឬទៅទាំងអស់គ្នា?

សំានលី ៖ ទៅទាំងអស់គ្នា ។

ធានី ៖ ទៅម៉ាពេទ្យនឹង?

សំានលី ៖ ចាស៎!

ធានី ៖ ពេទ្យនឹងមានផ្នែកអីគេខ្លះមីង?

ស៊ានលី ៖ នៅកន្លែងនឹង ពេទ្យនឹងមានតែកន្លែងឆ្មបនឹង ។

ធានី ៖ ឆ្មបនឹងគេធ្វើការងារដូចមីងនិយាយមិញនឹង?

ស៊ានលី ៖ ចាស៎! ធ្វើដូចតែគ្នា ។

ធានី ៖ ជួយដូចថាបង្កើតកូនអញ្ចឹង?

ស៊ានលី ៖ ជួយតើ!

ធានី ៖ ប៉ុន្មាននាក់ទៅមីង ដែលមកកើតនៅពេទ្យនឹង?

ស៊ានលី ៖ អ្នកបង្កើតនឹងគ្នាច្រើនដែរ ពេទ្យនឹងប្រហែលគ្នា ៣០នាក់អីដែរ ប៉ុន្តែតូចកំពស់ៗនឹងទៅ បង្កើតគេ មិនមែនធំទៅបង្កើតគេទេ ។ សុទ្ធតូចៗទាំងអស់គ្នា ហើយខ្ញុំកាលនឹងស្តើងហៀប ខ្ពស់វ្លៃ ។

ធានី ៖ កាលនឹងមីងអាយុប៉ុន្មាន តូចៗទៅរៀន?

ស៊ានលី ៖ តូចៗនឹងដូចថា បីបួន ប្រាំដប់ អីនឹងគ្មានលើសពីនឹងទេ ។

ធានី ៖ មីងកាលនឹងមីងអាយុប៉ុន្មានដែរ?

ស៊ានលី ៖ កាលនឹងខ្ញុំចូលពេទ្យនឹងអាយុ ១៦ឆ្នាំ ។

ធានី ៖ ហើយអ្នកទាំងអស់នឹង មានបទពិសោធន៍ធ្លាប់បង្កើតកូនដែរមីង?

ស៊ានលី ៖ អ្នកទាំងអស់គ្នានឹង សុទ្ធតែរៀនថ្មីដូចគ្នា ។ បង្កើតទៅរួចដូចគ្នា អត់មានអី ។

ធានី ៖ គេបង្រៀនម៉េចខ្លះ?

ស៊ានលី ៖ គេបង្រៀនយើង ដូចថាខ្ញុំកើតអញ្ចឹង ហើយប្អូនឯងនិងនាងហៅគ្នាទៅមើលអញ្ចឹង គេថា «អានេះកើតរបៀបនេះ ម៉ោងប៉ុននេះចាក់ថ្នាំ ម៉ោងនេះម៉ោងនោះមើលស្បូនគេបានបើក អញ្ចឹងណាស់» តែការពិត ខ្ញុំអត់បានទៅមើលគេអញ្ចឹងទេ ខ្ញុំនឹងដូចថាគេឈ្មោះ នេង ។ នេង នឹងគេអនុប្រធាន ដល់ពេលអ៊ីនោះគាត់ឈឺពោះ ខ្ញុំថា «នេង អញអត់ដឹងស្បូនអីទេ ម៉េចទៅ អញអត់បង្កើតទេ» «ចុះ! អាលីឯងចង់ដឹង អាលី ឯងមិនមើល!» យល់ហើយ ខ្ញុំលាងដៃស្អាត ខ្ញុំក៏បើកមើល ។ មើលឃើញកូននោះ បើក២សង់ទីម៉ែត្រ ខ្ញុំថា «នេង កូននោះ បើក២សង់ទីម៉ែត្រ» គាត់ថា «ស្បូននឹងដូចគូជមាន់យើងរកពងអញ្ចឹង» គេថា អញ្ចឹង ហើយខ្ញុំក៏ដឹងទៅ ។ ដល់មើលទៅ ឃើញអញ្ចឹងគ្រប់គ្នា ចេះកើតរួចបានទាំងអស់ ។

ធានី ៖ យើងអត់មានមើលទំហំរូបរាង ធម្មតាដូចថាក្មេងក្បាលចុះមិនចុះមានមើលដែរទេមីង?

សាំនលី ៖ មិនដឹងទេអូន ក្បាលចុះមិនចុះយើងមើលទៅ យើងតាមស្បូនក្បាលហើយ បើជើងយើងមើលទៅដឹងជើងហើយ យើងរាវទៅដឹងជើងហើយ ។

ធានី ៖ រាវដៃយើងអញ្ចឹងម៉េចទៅមីង?

សាំនលី ៖ រាវដៃយើងអញ្ចឹង ជើងនៅកន្លែងនឹង យើងរាវទៅយើងដឹង ។

ធានី ៖ យើងលូកដៃទាញដែរអត់?

សាំនលី ៖ ចាស៎! លូកដៃទាញ ។ លូកបានមួយយើងលូកមួយ លូកបានពីរយើងលូកពីរទៅ ។ ដល់ពេលហើយ យើងដឹងហើយថាក្បាលវាចុះមក ឬក៏ជើងវាចុះមក ហើយយើងប្រាប់ប្រធានថា "អ៊ីនេះជើងចុះមកក្រោម ក្បាលអត់ចុះមកទេ" ប្រាប់គេអញ្ចឹង យើងប្រាប់មុនខុសគេវៃចោល ភ័យណាស់ ។

ធានី ៖ ធ្លាប់មានទេមីង ដូចថាកើតមកជើងចុះក្រោម ក្បាលឡើងលើ?

សាំនលី ៖ មាន ។

ធានី ៖ មានច្រើនឬតិច?

សាំនលី ៖ មានអាណាក្បាលចុះទៅវាស្រួល អាណាជើងចុះបញ្ច្រាសវាពិបាក ។

ធានី ៖ ពិបាកម៉េចទៅមីង?

សាំនលី ៖ ពិបាកដល់រួចទៅ នៅត្រឹមករនឹង ។ បើថាអ្នកខ្លះមិនដឹង ទាញតែអានឹងមកវាផាប់ទាំងអស់ផ្លូវហើយមិននៅទេ ។ ដូចថាយើងធ្លាប់ដឹង យើងលូកដៃវាដាក់ក្នុងមាត់វា ហើយទាញចង្កាវាចុះមក មកល្វិត ហើយថាអានឹងនៅជាប់អានឹងមិនមកទេ ដល់អ្នកយើងអ្នកទាញវាឈប់មកហើយ ។ ហើយដល់ពេលមកអញ្ចឹង យើងរៀនចេះ ដូចថាខ្ញុំរៀនទៅប៉ុន្មានឆ្នាំអត់មានដែលបងប្អូនណាខូចខាត ចំពោះខ្ញុំម៉ែស្លាប់ដោយឆ្លងទន្លេអត់ទេ មានសួរបងប្អូនអ្នកស្រុកខ្លះ ខ្ញុំម៉ាឃុំកំពែងខ្ញុំបង្កើតសឹងតែទាំងអស់ ។

ធានី ៖ ពេលដែលមីងនិយាយថាម៉េចៗអញ្ចឹង គេបង្រៀនមីងមុនពេលធ្វើអញ្ចឹងឬមួយមីងចាប់ផ្តើមរៀនបណ្តើរធ្វើបណ្តើរ?

សាំនលី ៖ ចាស៎! រៀនបណ្តើរធ្វើបណ្តើរ អានឹងរៀនជាក់ស្តែងនឹងគ្មានរៀនអក្សរអីទេ ។

ធានី ៖ ខាងណាគេអ្នកមកបង្រៀន?

សាំនលី ៖ ខាងណាគេអ្នកមកនឹង គេមកជាមួយទ្រាំងស្មៀន ប្រធានគេនឹង ឈ្មោះ បងលី ។

ធានី ៖ បងលី នឹងគាត់ស្អីគេមីង?

សាំនលី ៖ គាត់ឆ្នបខេត្ត ហើយគេចុះមកតាមស្រុក ។

ធានី ៖ គាត់ចុះមកបង្រៀនមីង ឬមួយគាត់ចុះមកប្រចាំការ?

ស៊ានលី ៖ គេមកបង្រៀន ។

ធានី ៖ គេមកបង្រៀនរហូតឬក៏ម៉េច?

ស៊ានលី ៖ គេមកបង្រៀនយើងមិនសូវចេះច្បាស់លាស់ ។

ធានី ៖ បង្រៀនប៉ុន្មានខែមីង?

ស៊ានលី ៖ គេនៅយូរដែរ ។

ធានី ៖ ប្រហែលជាប៉ុន្មានទៅ?

ស៊ានលី ៖ នៅប្រហែល ៤ ៥ខែដែរ គេនៅជាមួយយើង ។ គេទៅបាត់ប្រហែល ៤ ៥ខែគេមកទៀត ។ គេមកមើលអីវ៉ាម៉េចអញ្ចឹង ។

ធានី ៖ ចុះម៉េច! បានគេទៅមកៗមីង?

ស៊ានលី ៖ គេទៅមកៗ គេចេញពីគេៗទៅកន្លែងនោះ ដូចគេចេញពីកន្លែងនោះគេទៅកន្លែងនោះទៀត ដល់អានឹងចប់ជុំគេមកដល់នឹងទៀត ។

ធានី ៖ អ្នកណាគេអនុប្រធានមីង?

ស៊ានលី ៖ អ្នកបង្រៀននឹងដូចថា បងរឿន នឹងគេប្រធាន បងឡេង នឹងគេអនុប្រធាន ។

ធានី ៖ មានបង ឡេង មួយទៀត?

ស៊ានលី ៖ បងឡេង គេអនុប្រធាន បងរឿន ។

ធានី ៖ ចុះ! បងនី នឹងគេអ្នកបង្រៀនដែរទេ?

ស៊ានលី ៖ បងនី នឹងគេអ្នកមកពីខេត្ត គេបង្រៀនអ្នកស្រុក ដល់អាខេត្តចេញអាស្រុកបង្រៀនយើងគ្រប់គ្នាអញ្ចឹងទៅ ។

ធានី ៖ អញ្ចឹងមីង! ដល់ពេលរៀននឹងរៀននៅណាវិញ?

ស៊ានលី ៖ រៀននៅគោកគ្រួស ។

ធានី ៖ មិនមែនរៀននៅសាលាយើងនេះទេ?

ស៊ានលី ៖ អត់ទេ!

ធានី ៖ ពេលមីងនៅនឹង មីងថាអ្នកជម្ងឺជាទាហាន ហើយប្រជាជន?

ស៊ានលី ៖ អ្នកជម្ងឺនឹង ខ្ញុំនៅកន្លែងពោះធំ មានតែឆ្លងទន្លេទេអូន ។

ធានី ៖ គោកនឹងដែរមីង?

ស៊ានលី ៖ អ្នកឆ្លងទន្លេនឹងនៅគោកគ្រួសនឹងដែរ ។

ធានី ៈ នៅក្នុងព្រៃ?

ស៊ានលី ៈ ក្នុងព្រៃជិតឈើង ខ្លាចចង់ងាប់ហើយយប់ឡើង ។

ធានី ៈ ចុះ! ពេលនៅក្នុងគោកគ្រួសនឹងនៅប្រហែលជាប៉ុន្មាន មីងបានមកនៅគីរីវង់យើងនេះ?

ស៊ានលី ៈ នៅយូរដែរ! មិនដឹងជាប៉ុន្មានយូរដែរណា ។

ធានី ៈ កាលនឹងដូចថា មីងនៅយូរអញ្ចឹង មីងមានឮថា ភ្នំពេញរំដោះបែកអីអញ្ចឹង មីងមានដែរឮទេ?

ស៊ានលី ៈ នៅគោកគ្រួសនឹងយូរណាណីដែរ មិនដឹងម៉េចគេផ្លាស់ឲ្យទៅនៅគីរីវង់នឹងទៅ ។

ធានី ៈ នៅគោកគ្រួសនឹង មីងធ្វើតែការងារឆ្មបអីអត់មានធ្វើការងារអី?

ស៊ានលី ៈ អត់! ធ្វើតែពេទ្យឆ្មបអញ្ចឹង ហើយយើងមើលអ្នកពោះធំ មើលអ្នកឆ្លងទន្លេ អត់មានធ្វើការងារអីទេ ។ ដូចថា គេធ្វើនឹងគេឆ្លាស់គ្នា ដូចថាពួកខ្ញុំម៉ាក្រុមនឹង ១០នាក់អញ្ចឹង ហើយអា១០នាក់នោះគេមិនទាន់មកព្យាបាល គេធ្វើការងារចូកពោនដំឡូង ដាំដំឡូងអីអញ្ចឹង ។ ហើយដល់ពេលយើងធ្វើហើយ យើងទៅធ្វើការងារនោះម្តង គេមកធ្វើអានឹងម្តង ។

ធានី ៈ អញ្ចឹង! មីងទៅណាវិញ ក្រៅពីធ្វើពេទ្យឆ្មប?

ស៊ានលី ៈ ពេទ្យឆ្មបនឹង ខ្ញុំអត់ទៅណានៅរហូតបែកជាមួយគេឯង ។

ធានី ៈ ចុះ! មីងប្រាប់ថាក្រៅពីការងារយើង មីងថាដាំដំឡូងអីណា?

ស៊ានលី ៈ ធ្វើដំណាំទៀត ។

ធានី ៈ ធ្វើដំណាំនឹង ចង់សួរថានៅកន្លែងណា?

ស៊ានលី ៈ ធ្វើនៅកន្លែងជិតគោកគ្រួសនឹងដែរ គេមានចំការគេលើអញ្ចឹងអូន ជិតជើងភ្នំអីអញ្ចឹងយើងទៅធ្វើ ។

ធានី ៈ ចុះ មីង គាត់ដែលសំរាលនឹងគាត់ប្រជាជននៅស្រុកយើង ឬជាប្រជាជនមកពីណាវិញ?

ស៊ានលី ៈ មានអ្នកថ្មី អ្នកចាស់លាយគ្នា ។

ធានី ៈ ពេលដែលគាត់មកសំរាលនឹងមីង?

ស៊ានលី ៈ ចាស៎!

ធានី ៈ អ្នកថ្មីនឹងមកពីណាមកវិញ?

ស៊ានលី ៈ មកទៅពីភូមិយើងទៅ ទៅពីឃុំអញ្ចឹងទៅអូន ទៅពីគុកព្រៃណាគេមើលមិនបាន គេបញ្ជូនទៅនឹងហើយ ។

ធានី ៖ អញ្ចឹង! បានន័យថា យើងមិនមានតែពេទ្យស្រុកមួយទេ យើងមានពេទ្យតាមឃុំៗអីពេទ្យឆ្នបមីង?

ស៊ានលី ៖ ពេទ្យភូមិ ពេទ្យឃុំ អីដូចថាគ្មានអ្នកមកកើតនឹងទេ កើតនៅស្រុកទាំងអស់ ។

ធានី ៖ គាត់ជាប្រជាជនថ្មី ឬជាប្រជាជនមកពីណាពីណី? អ្នកស្រុកយើងអ្នកស្រុកគីរីវង់អីអញ្ចឹងមានទេ មីង?

ស៊ានលី ៖ ចាស៎! មានអ្នកស្រុកគីរីវង់ តាមភូមិតាមឃុំអីអញ្ចឹងទៅ ។

ធានី ៖ អត់មានអ្នកក្រៅមក?

ស៊ានលី ៖ អត់មានទេ ។

ធានី ៖ សុទ្ធតែអ្នកស្រុកគីរីវង់ មកកើតកន្លែងមីង?

ស៊ានលី ៖ ចាស៎!

ធានី ៖ ចុះ! ដល់ពេលមីងមកដល់ស្រុកហើយ ទៅសាលាវិទ្យាល័យយើងដែលថានៅស្រុកអីមីងកន្លែងនឹង មានអ្នកថ្មីអីមកទៀត?

ស៊ានលី ៖ មាន! មានអ្នកថ្មីទៅ ។

ធានី ៖ អ្នកថ្មីមកពីណាវិញ?

ស៊ានលី ៖ មកពីភ្នំពេញ ។

ធានី ៖ ទៅដល់ស្រុកនឹងដែរ?

ស៊ានលី ៖ ចាស៎!

ធានី ៖ ទើបតែមកទេ?

ស៊ានលី ៖ ពេលបែកភ្នំពេញ ។

ធានី ៖ ញ្ចឹង! បានន័យថា ពេលបែកភ្នំពេញហើយ បានមីងគេផ្លាស់ប្តូរពីនៅគោកគ្រួសនឹង ទៅនៅវិទ្យាល័យនឹងដែរ ហើយបានមានអ្នកភ្នំពេញ គាត់មានផ្ទៃពោះគាត់មកសំរាលនឹងទៅ ។ អញ្ចឹង! បានមីងជួយមើលគាត់អីអញ្ចឹងមីង?

ស៊ានលី ៖ ចាស៎!

ធានី ៖ អញ្ចឹង! ឲ្យតែអ្នកមានផ្ទៃពោះ គាត់ត្រូវសំរាលនៅស្រុកទាំងអស់ អត់មានសំរាលនៅភូមិឃុំអីទេ?

ស៊ានលី ៖ ចាស៎! ដូចថា ពេទ្យឆ្នបឃុំ អត់ចំណាន ហើយគេធ្វើអត់កើតគេរុញទៅនឹងហើយ ។

ធានី ៖ អញ្ចឹង! ធ្វើម៉េចដឹងទៅ មីង? ធម្មតាស្រីយើងតែឈឺពោះហើយ ធ្វើម៉េចជួយទាន់មីង?

ស៊ានលី ៖ ដូចថា គេគ្រូនគេគ្មានលទ្ធភាពធ្វើ ដូចថាបញ្ច្រាសជើង ឬឈឺពោះពីរបីយប់ គេអត់ទុកទេ គេឲ្យទៅហើយ ។

ធានី ៖ ធម្មតា នៅភូមិឃុំធ្វើអត់បាន មីងទៅធ្វើយ៉ាងម៉េច?

ស៊ានលី ៖ ដល់ពេលវាឈឺពោះនៅយូរពេកអញ្ចឹង គេមើលៗតាមស្បូនគេដាក់សារ៉ូមដាក់អីទៅ ឈឺពោះកើតទៅ ។

ធានី ៖ សារ៉ូមនឹងសារ៉ូមអីគេ មីង?

ស៊ានលី ៖ សារ៉ូម ដូចប្រាប់អញ្ចឹង ថាគេស្ទួគេដាក់ដបដូចយើងអញ្ចឹងទៅ គេធ្វើពីស្អីមកខ្ញុំក៏មិនដឹងដែរ ។

ធានី ៖ ដបអីគេទៅ?

ស៊ានលី ៖ ដបធំៗ ។ ដបនឹងដូចយើងអាស្រាបួនជ្រុងប៉ុននឹងអញ្ចឹង ចូលតាមអានឹងមិនដឹងគេដាក់អីខ្លះ ។

ធានី ៖ ថ្នាំនឹងមកពីណាមកវិញ?

ស៊ានលី ៖ ខ្ញុំប្រាប់ថ្នាំគេស្ទួនឹង គេស្ទួតាមស្រុកតាមឃុំ ហើយគេបញ្ជូនទៅឲ្យយើងទៅ ។

ធានី ៖ ហើយថ្នាំនឹងគេធ្វើអីខ្លះ?

ស៊ានលី ៖ បើខ្ញុំអត់ដឹងគេធ្វើអីខ្លះ អត់ដឹងអូនមិននៅកន្លែងក្រុមថ្នាំនឹងទេ ខ្ញុំដឹងតែពីបង្កើត ។

ធានី ៖ ចុះ! មីងម៉េចដឹងថា ថ្នាំនឹងសម្រាប់ចាក់សម្រាប់សំរាលកូនអីអញ្ចឹង?

ស៊ានលី ៖ ដូចថាគេប្រធានគេដឹង គេធ្លាប់គេបង្រៀនយើងអញ្ចឹងទៅ ។

ធានី ៖ ហើយថ្នាំនឹង គេដាក់ផ្លាកថាម៉េច?

ស៊ានលី ៖ គេដាក់ផ្លាកថា សារ៉ូមផ្អែមប្រៃ សារ៉ូមផ្អែម សារ៉ូមប្រៃ ។

ធានី ៖ គេដាក់តែប៉ុននឹង?

ស៊ានលី ៖ ចាស៎! ដាក់តែប៉ុននឹង មិនដឹងដាក់អីទេ ។

ធានី ៖ ចុះមុនពេលសំរាល មីងធ្វើអីខ្លះ? ដើម្បីយើងដឹងថា មិញមីងប្រាប់ថាមុនពេលសំរាល មីងប្រាប់ថាមានដឹង មើលតាមពោះមើលតាមក្បាល ។ អញ្ចឹង! ពេលសំរាលយើងត្រូវធ្វើអីខ្លះ?

ស៊ានលី ៖ ពេលសំរាលហើយ?

ធានី ៖ អត់ទេ! ពេលកំពុងសំរាល ។

សាំនលី ៖ ពេលកំពង់សំរាល មានប្រធានគេៗចេះដាងយើង ធ្វើហើយគេដើរចេញហើយឲ្យយើងក្រោយ ក្មេងៗគេឲ្យយើងជូតលាងស្អាតបាទហើយ លើកគាត់មកដាក់លើគ្រែ អារឿងថ្នាំគេផ្សេងទេ ។

ធានី ៖ អញ្ចឹង! ពេលមីងមកដល់ស្រុកហើយ បានគេចាត់ឲ្យមីងដឹងតែបង្កើតទេ ដល់ហើយលែងប៉ះពាល់រឿងអញ្ចឹង ។ ដល់ពេលនៅភូមិគោកគ្រួសនឹង បានមីងធ្វើដូចថា ចាក់ថ្នាំចាក់អីជាមួយគេបង្កើតខ្លួនឯងខ្លះឬក៏បង្កើតជាមួយគេ?

សាំនលី ៖ ចាស៎! បង្កើតខ្លួនឯងខ្លះអញ្ចឹងទៅ អាប្រធានអនុប្រធានគេមិននៅ នៅតែឯងឯណាអាម៉ីអាថៅងអីអញ្ចឹងទៅ នាំគ្នាធ្វើហើយ អាខ្លះដាំទឹកទៅ អាខ្លះមកមើលគេអញ្ចឹង ។ ដល់ពេលដាំទឹកបាននាំគ្នា ជួយធ្វើគ្នាទៅរត់អាញ៉ែទៅ ។

ធានី ៖ ចុះ! មីង ដូចថា ឆ្មបលាយជាមួយសម័យឬក៏បុរាណកាលសម័យ ប៉ុល ពត?

សាំនលី ៖ កាលសម័យ ប៉ុល ពត បុរាណលាយបុរាណតែម្ដង ដូចថាចាក់ថ្នាំចាក់អីមានតែពេទ្យគេចាក់ទៅ ។

ធានី ៖ ហើយមានជាការអុចធូបជាអីអញ្ចឹងដែរអត់?

សាំនលី ៖ អត់មានទេ! គេអត់មានជំនឿអញ្ចឹងទេ ។

ធានី ៖ ចាំតែយើងតែអ្នកបង្កើត ហើយយើងចាក់ថ្នាំ?

សាំនលី ៖ ចាស៎! តែមានដុតធូប ងាប់មិននៅទេ ចេះធ្វើអានឹងគេបំបាត់ចោលអស់ ។

ធានី ៖ អញ្ចឹង! មីងមានដឹងថានៅស្រុកយើង សាលាវិទ្យាល័យគិរីវង់សព្វថ្ងៃនឹង ពេលទៅដល់ពេទ្យស្រុកនឹង អ្នកណាគេអ្នកធ្វើប្រធាន?

សាំនលី ៖ អាប្រធានយើងគេនៅប្រធានដ៏ដែរ ប្រធានពីគោកគោកគ្រួសទៅ ហើយអាប្រធានមួយមិញនឹងប្រធានគេទូទៅ ប្រធានគេផ្សេងចខាងទូទៅ ។

ធានី ៖ ចុះមានប្រធានធំទេ? ដូចថាពេទ្យអញ្ចឹង មានទេមីង ដូចជាប្រធានពេទ្យ?

សាំនលី ៖ ប្រធានធំគេ នែអញ្ចេះអូន! បានថាអ៊ីមិនសូវដឹង ដូចថានៅតូចៗនឹងមិនសូវដឹងថាអាណាធំអាណាតូចអីទេ ។ ដឹងថាមួយនឹងប្រធានយើង មួយនេះអនុប្រធានយើងអញ្ចឹងតែម្ដង វាអត់ដឹងថាអាណាធំជាងអាណា មកពីណានោះទេ ។

ធានី ៖ អញ្ចឹង! មីងគ្រាន់ដឹងថា យាយរឿន នឹង ប្រធានរបស់មីងប្រធានឆ្មប ហើយមួយទៀតអនុប្រធាន ។ ហើយបងលី នឹង?

សាំនលី ៖ បងលី នឹងគេប្រធានមកពីខេត្តអញ្ចឹងតែម្ដង ។

ធានី ៖ ចុះ! បងលី គេផ្លាស់ទៅនៅស្រុកគីរីវង់ ទៅដែរអត់?

ស៊ានលី ៖ អត់! ទៅឈប់ទៅហើយ ។

ធានី ៖ ទៅតែមីង ហើយនិងពេទផ្សេងៗ?

ស៊ានលី ៖ ចាស៎!

ធានី ៖ អញ្ចឹង! ពេលដែលមីងនៅពេទ្យ មានអ្នកផ្ទៃពោះប៉ុន្មាននាក់ មកសំរាលនៅពេទ្យ?

ស៊ានលី ៖ អ្នកជម្ងឺ? ហូរហែលអូន! ១០ ២០ ៣០អញ្ចឹងទៅ ហូរហែលអត់ដាច់ទេ ។

ធានី ៖ អញ្ចឹង! ពេលដែលមីង ជាធម្មតាពេលដែលប្រធានអត់នៅអញ្ចឹង ជាមួយនឹងអ្នកផ្សេងធ្វើម៉េចខ្លះ? ដូចថាព្យាបាលម៉េចអីម៉េច?

ស៊ានលី ៖ ព្យាបាល ដូចថាគេឈឺមុនពេលកើតគេឈឺក្តៅឬក្អក យើងព្យាបាលតាមនឹង ។

ធានី ៖ តាមនឹងមីង?

ស៊ានលី ៖ ដូចថាគេក្អក ពេលកើតគេក្អក គេធ្លាក់ស្បូនធ្លាក់អីយើងប្រើងគេឲ្យជាពីមុន ។

ធានី ៖ អញ្ចឹង! ក្រៅពីប្រធានរបស់មីង អត់មានស្គាល់អ្នកផ្សេងទៀតទេ?

ស៊ានលី ៖ អត់!

ធានី ៖ ចុះ! មីងធ្លាប់មកលេងផ្ទះមីងដែរទេ ពេលដែលនៅស្រុកនឹង?

ស៊ានលី ៖ ខ្ញុំមិនមកទេ ម៉ែឪខ្ញុំស្លាប់អស់ហើយ ខ្ញុំមិនដឹងមកលេងខាងណា នៅនឹងគេនឹងឯងនោះ ។

ធានី ៖ ចុះ! ម៉េចបានមីងដឹងម៉ែឪស្លាប់?

ស៊ានលី ៖ ហូ! ម៉ែឪខ្ញុំស្លាប់ ពេលស្លាប់ខ្ញុំមក គាត់ស្លាប់អស់ហើយ ខ្ញុំឈប់មកទៅៗមកក៏លែងគ្មានអ្នកណា ព្រោះបងខ្ញុំទៅកងទ័ពបាត់ហើយ ។

ធានី ៖ មីងកាលនឹងឪពុកមីងស្លាប់នៅឆ្នាំប៉ុន្មានមីង?

ស៊ានលី ៖ ឪខ្ញុំស្លាប់ប្រហែលជិតប៉ុន្មានទេ ព្រោះអាពត បានបីឆ្នាំឪខ្ញុំស្លាប់ ឆ្នាំប៉ុន្មានអូនមិនដឹង ។

ធានី ៖ កាលនឹងមីងផ្លាស់ទៅនៅគីរីវង់នៅ?

ស៊ានលី ៖ អត់ទេ! ខ្ញុំនៅគោកគ្រួស ឪខ្ញុំស្លាប់នឹងទៅ ។

ធានី ៖ គាត់ស្លាប់ដោយសារអីគេមីង?

ស៊ានលី ៖ គាត់ដូចថាហូបមិនឆ្អែត ហើម ។

ធានី ៖ ម៉េចបានហូបមិនឆ្អែតអញ្ចឹងមីង?

ស៊ានលី ៖ វាអត់មានជីវជាតិបន្ថែមអីអូន បាយបបរនឹងលាយដំឡូងមីនឹង ។

ធានី ៖ ហូបរួមហើយមីង?

សំានលី ៖ ចាស៎!

ធានី ៖ តែកាលនឹងមានតែប្រជាជនចាស់ទេ អត់មានប្រជាជនថ្មីមកច្រើនមើង?

សំានលី ៖ កាលឪខ្ញុំស្លាប់ មិនទាន់បែកអ្នកថ្មីមកទេ មិនទាន់ឃើញអ្នកថ្មីផង ។

ធានី ៖ ចុះ! ម្ដាយមីង?

សំានលី ៖ ម៉ែខ្ញុំស្លាប់ក្រោយឪខ្ញុំ មានអ្នកថ្មី ។

ធានី ៖ មានអ្នកថ្មីហើយ?

សំានលី ៖ ចាស៎!

ធានី ៖ កាលនឹងដូរគីរីវង់ហើយ?

សំានលី ៖ អត់ទាន់ដូរទៀតនៅគោកគ្រួសនៅឡើយ ។

ធានី ៖ ប៉ុន្តែមានអ្នកថ្មីមកហើយ?

សំានលី ៖ ចាស៎! មានអ្នកថ្មីមក ។

ធានី ៖ អ្នកថ្មីមកពីណាវិញ?

សំានលី ៖ អ្នកថ្មីពីភ្នំពេញ បែកភ្នំពេញ ។

ធានី ៖ មីងមិញប្រាប់ខ្ញុំថា អ្នកថ្មីផ្លាស់មកហើយ មីងទៅដល់សាលាគីរីវង់ នៅវិទ្យាល័យពេទ្យស្រុកនឹង អញ្ចឹងមីង?

សំានលី ៖ ចាស៎!

ធានី ៖ ហើយបន្ទាប់មកទៀតម្ដាយមីងស្លាប់ តែអ្នកថ្មីមកដែរ?

សំានលី ៖ ខ្ញុំវាអត់សូវចាំដែរ ខ្ញុំនៅស្ទើរតូចដែរ ។

ធានី ៖ អញ្ចឹងមីង គិតមើលដូចថា ប្រហែលជាតម្ដាយមីងទើបតែស្លាបហើយ បានមីងផ្លាស់ប្ដូរពីអាគោកគ្រួសនឹងមក ឬមីងផ្លាស់ហើយបានម្ដាយមីងមក? មួយណាមុនមួយណាក្រោយមីង?

សំានលី ៖ ឪខ្ញុំស្លាប់ខ្ញុំនៅគោកគ្រួស ម៉ែខ្ញុំស្លាប់ខ្ញុំនៅគីរីវង់ គេបញ្ជូនម៉ែខ្ញុំទៅពេទ្យ ។

ធានី ៖ មីងបានជួបគាត់ដែរ?

សំានលី ៖ ចាស៎! ជួបម៉ែខ្ញុំនៅពេទ្យ ។

ធានី ៖ ហើយជួយព្យាបាលគាត់ដែរ មីង?

ស៊ានលី ៖ គេចូលកន្លែងតែនឹង ម៉ែខ្ញុំនៅជម្ទីទូទៅគាត់ឈឺ ហើយគេឲ្យទៅចូកស្មៅក្រុម ហើយគាត់លួចស្លាប់ទៅ ។ ខ្ញុំគ្រាន់បាន កន្លែងនឹងកន្លែងទូទៅទេ ខ្ញុំឆ្លងទៅមើលម៉ែ កន្លែងនេះកន្លែងនេះ កន្លែងឆ្នបអញ្ចឹងអូន ។

ធានី ៖ ហូ! យើងបានមើល យើងអត់បានជួយព្យាបាលគាត់បាន?

ស៊ានលី ៖ ចាស៎! អត់បានជួយព្យាបាលម៉ែទេ អានឹងរឿងគេផ្សេង ។

ធានី ៖ អញ្ចឹងបានន័យថា ម្ដាយរបស់មីងព្យាបាលនៅស្រុកនឹងជាហើយ បានត្រឡប់ទៅផ្ទះវិញ?

ស៊ានលី ៖ អត់ជាទេ ដឹកមកដល់ផ្ទះបានមួយយប់ស្លាប់ ។

ធានី ៖ គាត់ឈឺអីគេមីង?

ស៊ានលី ៖ គាត់ឈឺអីពីមុន ដក់គាត់ឈឺហើយហើមជើងអូន ។ ហើមអញ្ចឹង រួចទៅគេប្រើគាត់ឲ្យទៅចូកស្មៅក្រុមគេប្រលក់ក្រុមា ដល់ពេលហើយគាត់លួចចូកនឹងក៏ស្លាប់ទៅ ។

ធានី ៖ គាត់ធ្វើការទាំងឈឺមីង?

ស៊ានលី ៖ ចាស៎! គេឲ្យធ្វើទាំងឈឺនឹង ។

ធានី ៖ អ្នកណាគេមីង?

ស៊ានលី ៖ ចុះមេអាពតអូន!

ធានី ៖ មានស្គាល់ឈ្មោះគាត់ទេ?

ស៊ានលី ៖ មេអាពតនឹង ឈ្មោះ ពូហាយ តែគាត់ងាប់បាត់ហើយ ។

ធានី ៖ ពូហាយ នឹងអ្នកណាគេមីង?

ស៊ានលី ៖ ពូហាយ នឹងគេប្រធាននៅនឹងតែម្ដង ប្រធាននៅកង

ធានី ៖ មេកងនៅភូមិយើងមីង?

ស៊ានលី ៖ ចាស៎!

ធានី ៖ ហើយ ពូហាយ នឹងអ្នកឲ្យម្ដាយមីងនឹងចូកស្មៅក្រុមនឹង?

ស៊ានលី ៖ ចាស៎!

ធានី ៖ ធម្មតាពេទ្យនៅភូមិនៅឃុំអី គេព្យាបាលមិនជាបានបញ្ជូនទៅពេទ្យស្រុក?

ស៊ានលី ៖ គេព្យាបាលមិនជា គេបញ្ជូនទៅដល់នឹង ហើយដល់មើលទៅម៉ែមិនធូរទេ ហើយអញ្ចឹង! សហករណ៍ គេដឹកសុទ្ធរទេះសេះ ហើយគេគ្រាន់ប្រាប់ថា "អត់ធូរទេ យកមកផ្ទះវិញ" យកមកផ្ទះវិញ បានស្លាប់?

ធានី ៖ ហើយមីង មិនព្យាយាមជួយគាត់? ធម្មតាធ្វើពេទ្យជាមួយគ្នា ស្គាល់អ្នកនេះៗអីអញ្ចឹង មានសុំឲ្យគេជួយអីដែរ?

សាំនលី ៖ អាំនឹងសុំឲ្យគេជួយដែរ គេថាគេជួយយើងមិនបាន ។

ធានី ៖ សុំខាងណាវិញ មីង?

សាំនលី ៖ សុំពេទ្យនឹង ។

ធានី ៖ សុំអ្នកណាគេ ឈ្មោះអី?

សាំនលី ៖ នៅពេទ្យនឹង ខ្ញុំវាអត់ដឹងច្បាស់ថា ប្រធានគេឈ្មោះអី ។

ធានី ៖ ប៉ុន្តែបានទៅសុំគេដែរ?

សាំនលី ៖ ចាស៎! សុំថា "ជួយមើលម៉ែខ្ញុំផង ម៉ែខ្ញុំឈឺខ្លាំងណាស់" ដល់ហើយគេថា "គាត់ជួយមិនបានមិន គាត់ខ្លាំងពេកហើយ" ។

ធានី ៖ ពេលដែលមីងនៅពេទ្យអញ្ចឹង អ្នកណាគេអ្នកធំនៅស្រុកគីរីវង់យើងនេះ?

សាំនលី ៖ នៅពេទ្យគីរីវង់នឹង អ្នកណាគេគ្រប់គ្រង គណៈស្រុកគេ?

ធានី ៖ ចាស៎!

សាំនលី ៖ គណៈស្រុកគេ ឈ្មោះ តាគុំ ។

ធានី ៖ តែម្នាក់គាត់នឹងទេ?

សាំនលី ៖ តាគុំ នឹងគេប្រធានខាងប្រុសៗអញ្ចឹង គេមើលគ្រប់គ្រងម៉ាស្រុកអញ្ចឹង ហើយដល់បងយឿនមើលខាងស្រីអញ្ចឹងម៉ាស្រុកអញ្ចឹង ។

ធានី ៖ តែមើលតែស្រីយើងពេទ្យ?

សាំនលី ៖ មើលទូទៅទាំងអស់ តែគាត់ត្រួតពិនិត្យកន្លែងធ្វើការវាញឹកញាប់ជាង ។

ធានី ៖ ធ្វើការណាមីង?

សាំនលី ៖ បងយឿន នឹងគេមកត្រួតពិនិត្យយើង ។

ធានី ៖ នៅពេទ្យនឹង?

សាំនលី ៖ ចាស៎!

ធានី ៖ ចុះ! ក្រៅពីតាគុំ មានអ្នកណាផ្សេងទៀតទេ?

សាំនលី ៖ ក្រៅពីតាគុំគេប្រធាន តាទិត្យគេនឹងអនុ ។

ធានី ៖ មានតែពីរនាក់នឹង អត់មានផ្សេងទៀត?

សាំនលី ៖ ខ្ញុំអត់ដឹងអត់ស្គាល់ទេ ខ្ញុំស្គាល់តែពីរនាក់នឹង ។

ធានី ៖ បងយឿន នឹងគាត់នៅខាងណាវិញ?

ស៊ានលី ៖ គាត់ខាងនារីយើងអញ្ចឹង ខាងនារីត្រួតត្រា ។

ធានី ៖ មើលពេទ្យអញ្ចឹង?

ស៊ានលី ៖ ចាស៎!

ធានី ៖ មើលតែមីងទេ ឬមើលអ្នកផ្សេងទៀត?

ស៊ានលី ៖ គេមើលទូទៅ ត្រួតពិនិត្យទាំងអស់ ។

ធានី ៖ ដូច តាតុំ តាទិត្យ អីដែរ?

ស៊ានលី ៖ ចាស៎!

ធានី ៖ អត់មានអ្នកផ្សេងទៀតមីង?

ស៊ានលី ៖ អត់ទេ!

ធានី ៖ ចុះបន្ទាប់មកទៀតមានការផ្លាស់ប្តូរអីទេ?

ស៊ានលី ៖ ខ្ញុំអត់ស្គាល់ដឹងតែប៉ុននឹង ។

ធានី ៖ ដឹងតែប៉ុននឹង?

ស៊ានលី ៖ ចាស៎!

ធានី ៖ អញ្ចឹង! ក្រោយមកទៀត មីងយឿន ឧស្សាហ៍មកមើលមីងធ្វើការធ្វើងារអី?

ស៊ានលី ៖ ចាស៎!

ធានី ៖ អញ្ចឹង! តាតុំ តាទិត្យ ធ្លាប់មកមើលទេ?

ស៊ានលី ៖ អត់ទេ!

ធានី ៖ អញ្ចឹងម៉េច! បានមីងដឹងថា?

ស៊ានលី ៖ ខ្ញុំស្គាល់គេ ដូចថាគេធំជាងខ្ញុំអញ្ចឹងគេថា តាតុំ នឹងគណៈស្រុក គេថា តាទិត្យ នឹងអនុតាតុំ គេថាអញ្ចឹង ។

ធានី ៖ ឃើញតែពីរនាក់ទៀត?

ស៊ានលី ៖ ចាស៎!

ធានី ៖ ពេលដែលមីងនៅពេទ្យនឹង នៅដល់ប៉ុន្មានឆ្នាំបានមីងដូរ?

ស៊ានលី ៖ នៅពេទ្យគោកគ្រួសនឹង?

ធានី ៖ អត់ទេ! នៅពេទ្យគីរីវង់ ។

សាន់លី ៖ នៅពេទ្យគីរីវង់នឹង ដល់បែកគ្នាបែកអាពតនឹង ដល់យួនបុកមកដល់បែកអាពត បានបែកគ្នាទៅ ហើយមិនដឹងប៉ុន្មានទេ ។

ធានី ៖ មិនដឹងប៉ុន្មាននាក់អញ្ចឹង?

សាន់លី ៖ ចាស៎!

ធានី ៖ អញ្ចឹង! សុំបកក្រោយបន្តិចកន្លែងមីងថា នៅក្នុងគោកគ្រួសនៅក្នុងព្រៃនឹង មីងថាមានវៀតណាម បេះធ្វើឆ្កែចចក គេធ្វើអញ្ចឹងធ្វើអីមីង?

សាន់លី ៖ មិនដឹងដែរ ។

ធានី ៖ ចុះ! កាលនឹងមីងហូបចុកម៉េចដែរ?

សាន់លី ៖ ហូបចុកវាអត់ឆ្អែតអត់អីទេអូន លាយបបរលាយដំឡូងមី ។

ធានី ៖ ចុះ! មីងមកដល់ស្រុកគីរីវង់ហើយ ស្រុកនឹង...

សាន់លី ៖ មកដល់គីរីវង់នឹង គេឈប់ដាក់ដំឡូងមីនឹង បបរធម្មតា ។

ធានី ៖ ចុះ! អ្នកជម្ងឺហូបម៉េចទៅ?

សាន់លី ៖ អ្នកជម្ងឺក៏ហូបអញ្ចឹងដែរ ។

ធានី ៖ ហូបដូចមីងដែរ?

សាន់លី ៖ ចាស៎! អ្នកជម្ងឺម៉េច យើងអញ្ចឹង ។

ធានី ៖ ធម្មតា គាត់ឈឺអីអញ្ចឹង គាត់មិនសូវមានកម្លាំង ហូបតែបបរហូបអីនឹង ឬក៏មានអីថែមពីលើនឹង?

សាន់លី ៖ បបរ សំល្ងស្លឹកដំឡូងឆ្វៀល ស្លឹកដំឡូងមី អញ្ចឹងអូន ។

ធានី ៖ មានអីលើសពីនឹងមីង?

សាន់លី ៖ គ្មានទេ! ដូចថាបន្លែត្រឡាចអីអញ្ចឹងខ្លះទៅ មានបន្លែអីដែលយើងចង់អីបាននោះទេ ។

ធានី ៖ អត់មានទេមីង?

សាន់លី ៖ អត់ទេ!

ធានី ៖ អញ្ចឹង! ពេលមីង បែកវៀតណាមចូលមកដល់ មីងក៏រត់ទៅណា?

សាន់លី ៖ រត់ទៅណាទៅណីអញ្ចឹង ដល់ហើយមានប្ដីអញ្ចឹង ទៅនៅស្រុកប្ដីអញ្ចឹងនៅផ្ទះ ។

ធានី ៖ ស្រុកគាត់នៅណាវិញមីង?

សាន់លី ៖ នៅផ្ទះអង្គប្រាសាទ គីរីវង់ ដែរ ។

ធានី ៖ ឃុំអីគេមីង?

សៀានលី ៖ ឃុំអន្លូង្រាសាទ ។

ធានី ៖ មីងមានគ្រួសារឆ្នាំណាដែរ?

សៀានលី ៖ អូនអើយ! មានគ្រួសារគ្មានដឹងឆ្នាំអីទេ ។

ធានី ៖ ប៉ុន្តែនៅសម័យខ្មែរក្រហម ឬក្រោយមកហើយ?

សៀានលី ៖ មានប្តីសម័យ ប៉ុល ពត នឹងតែម្តង ។

ធានី ៖ ពេលមីងស្គាល់គាត់ ម៉េចបានមីងស្គាល់គាត់អីអញ្ចឹង?

សៀានលី ៖ មិនស្គាល់ទេអូន! ទៅនឹងគេហៅ ប៉ុន្តែកាលនឹងគេរៀបតែពីរគូទេ ។ ក្រៅពីនឹងលេងដូរ ក្រមាក្នាខ្សែទាំងខ្សែ ហើយប្រុសឲ្យក្រមាស្រី ហើយស្រីឲ្យក្រមាប្រុស ចំណាំក្រមាមិនស្គាល់ប្តីនឹងមុខម៉េចទេ ។ ហើយខ្ញុំនឹង ខ្ញុំមិនដឹងអីផង គេហៅទៅនឹងមិនដឹងថាគេទៅធ្វើអញ្ចឹងទេ ។ ខ្ញុំមិនព្រមយក គេលើកស៊ុយកាំភ្លើងវៃខ្ញុំ ហើយខ្ញុំខ្លាចងាប់ខ្ញុំយកទៅ ។

ធានី ៖ ខាងណាគេមកហៅមីង?

សៀានលី ៖ រដ្ឋអំណាច ប៉ុល ពត នឹងតែម្តង ។

ធានី ៖ ឈ្មោះអីគេមីង?

សៀានលី ៖ ឈ្មោះ ពូអូន ។

ធានី ៖ ពូអូន នឹងគាត់ធ្វើអីគេ?

សៀានលី ៖ គាត់ធ្វើខាងរដ្ឋអំណាចខាងយោធានឹង ។

ធានី ៖ យោធានៅណាវិញមីង?

សៀានលី ៖ យោធានៅស្រុកគិរីវង់ដែរ ។

ធានី ៖ កន្លែងគាត់នៅណាវិញ?

សៀានលី ៖ កន្លែងនៅស្រុកនឹងតែម្តង ។

ធានី ៖ នៅស្រុកក្បែរមីងដែរ?

សៀានលី ៖ នៅស្រុកម្រាមអណ្តើត ភូមិម្រាមអណ្តើតនឹង ។

ធានី ៖ ចុះ! ធ្វើការគាត់នៅណាវិញ?

សៀានលី ៖ កន្លែងធ្វើការគេនៅនឹងតែម្តងអូន ហើយគេយកយើងទៅរៀបនឹង ។

ធានី ៖ ហើយកាលនឹង ម៉េចមីងបានដឹងថា គេយកមីងទៅរៀប?

សៀានលី ៖ ខ្ញុំអត់ដឹងផង! គេមកហៅ ខ្ញុំអ្នកចុងភៅទៅធ្វើបាយធ្វើសំល្លគេមកប្រជុំ ហើយខ្ញុំធ្លាប់ទៅ

អញ្ចឹងរាល់ដង ដងនឹងគេកុហសខ្ញុំថា ទៅធ្វើបាយធ្វើសំល្ល ។ ខ្ញុំទៅដល់មិនទៅរកកន្លែងចង្ក្រានឆ្នាំង? ហើយគេថាថ្ងៃនឹងអត់ធ្វើបាយធ្វើសំល្លទេ ថ្ងៃនឹងគេរៀបឲ្យឯង ខ្ញុំថា «រៀបអីគេ?» «ហើយចុះ! ឯងអត់ចង់បានប្តីទេ?» ថា «អត់ទេ! ខ្ញុំអត់ចង់បានប្តីទេ» ។ ពេលនឹងខ្ញុំមិនព្រម ខ្ញុំប្រកែកគេរកវ៉ៃខ្ញុំនឹងស៊ុយកាំភ្លើងខ្ញុំខ្លាច ទល់តែយូរ!អូនឯងមិនយកសាប់ យកទៅ ។

ធានី : ហើយគេធ្វើម៉េចខ្លះ ពេលពិធីយក?

ស៊ានលី : គេឲ្យយើងប្តេជ្ញា! មានធ្វើអីណា ប្តេជ្ញា!យកគ្នាម៉ាជីវិតអញ្ចឹង ម៉ាហិចតា៣គោនទៅ៦គោនអញ្ចឹងណាស់! ហើយខ្ញុំមិនប្តេជ្ញា!ទេ ថ្ងៃណាគេវ៉ៃសាប់ ប្តេជ្ញា!តែខាងប្រុសទេ ខាងស្រីមិនព្រម ខ្ញុំអត់ប្តេជ្ញា!ទៀត ។

ធានី : មីងម៉ាគូ ហើយអ្នកណាម៉ាគូទៀត?

ស៊ានលី : ខ្ញុំម៉ាគូ ម្នាក់គូទៀតឈ្មោះ មឿន ស្រីនឹង ហើយប្តីគេឈ្មោះ យឿន ។

ធានី : គាត់មកពីណាវិញមីង?

ស៊ានលី : អានឹងគេខាងសប្បិកម្មតល្បាញ ហើយពូនោះខាងដីដែក ។ ហើយខ្ញុំខាងពេទ្យ ប្តីខ្ញុំធ្វើការនៅអគ្គការដែរ កន្លែងចំការអូនធ្វើដាំនេះដាំនោះអីអញ្ចឹង ។

ធានី : គាត់ប្រធានគេ ឬមួយសមាជិកដូចមីងដែរ?

ស៊ានលី : អត់ទេ! សមាជិកអូន ។

ធានី : ដល់ពេលធ្វើពិធីប្តេជ្ញាហើយ បន្ទាប់មកទៀត គេធ្វើអីទៀត?

ស៊ានលី : អត់ធ្វើអីផង!

ធានី : ចុះពេលនឹងមីងនៅឯណា?

ស៊ានលី : ខ្ញុំនៅគោកគ្រួស គេប្តេជ្ញា ។

ធានី : ដល់ពេលហើយមីងទៅណាទៀត?

ស៊ានលី : ប្តេជ្ញាហើយអញ្ចឹង ខ្ញុំនៅពេទ្យនឹងប្រហែលកន្លះខែ ។ ខ្ញុំវាអញ្ចែង នៅជំនាន់ ប៉ុល ពតនឹងនារីនិងយុវជននិយាយចូលគ្នាមិនបានទេ គេវ៉ៃសាប់! ហើយខ្ញុំអត់ន័យថា ប្តីប្រពន្ធនឹងវាម៉េចទេ ។ ថា «និយាយចូលគ្នាគេវ៉ៃសាប់ ចុះ!ពូឯងមកដេកជាមួយខ្ញុំ គេវ៉ៃខ្ញុំសាប់ហើយ» ។ ហើយអញ្ចឹងប្តីថា «អត់វ៉ៃទេអញ្ចឹង» ។ អត់មានត្រូវប៉ះពាល់អីគ្នាអត់ទេ ហើយគេថាយើងនៅនឹងអញ្ចឹងត្រូវគ្នា គេបញ្ជូនខ្ញុំទៅនៅសហករណ៍ខាងបរគុលខាងភូមិព្រៃរំដេង ។ ដល់ហើយ ផ្ទះនឹងគេឲ្យនៅឆ្ងាយដាច់អុន មិនមែននៅជាប់គ្នាទេ ។ ផ្ទះខ្ញុំគេឲ្យដាច់ពី

គេ ហើយអញ្ចឹងខ្លាចផ្អែចចក ដើមស្វាយធំៗនៅក្រោយផ្ទះ យប់ព្រលប់មិនទាន់ទេ ផ្អែ ចចកលូហើយ ។ ដល់ហើយអញ្ចឹង ចាំប្តីចាំមើលផ្លូវហើយ ខ្លាច! បានមកនៅនឹងបានត្រូវគ្នានឹង មិននឹងអត់ទេ ខ្លាចគេវៃសាប់ ។

ធានី : មីងនៅធ្វើពេទ្យរហូត?

ស៊ានលី : ចាស៎!

ធានី : មីងមានគ្រួសារហើយ ក៏ឈប់ធ្វើទៅ?

ស៊ានលី : ខ្ញុំឈប់ធ្វើហើយ ។

ធានី : អញ្ចឹង! មីងធ្វើអីទៅ?

ស៊ានលី : ខ្ញុំនៅសហករណ៍នឹងគេទៅ ស្ទូង ដក ច្រូត ។

ធានី : អញ្ចឹង! ប្រធានសហករណ៍មីងឈ្មោះអី?

ស៊ានលី : ខ្ញុំភ្លេចឈ្មោះគេហើយ មិនដឹងឈ្មោះអី ពូនឹងនៅបរគុល ខ្ញុំភ្លេចឈ្មោះគេហើយ

ធានី : កាលនឹងមីងមានចាំទេ? កាលនឹងប្រហែលជាប៉ុន្មាន ឬបែកគ្នានៅ?

ស៊ានលី : ក្នុងសហករណ៍បានបន្តិចដែរ បែកគ្នា ។

ធានី : ប្រហែលជាប៉ុន្មានមីងមានចាំទេ?

ស៊ានលី : មិនដល់ឆ្នាំទេ បែកគ្នា ។

ធានី : ហើយមីងនៅជាមួយគាត់រហូតឬក៏ម៉េច?

ស៊ានលី : ខ្ញុំបែកគ្នា ប្តីដើររក ទៅជួបគ្នានៅមរោមយើងនេះ ។

ធានី : មរោមនៅណាមីង?

ស៊ានលី : មរោមនឹងនៅលិចនេះ នៅលិចគានីៗ ដល់ហើយគេហៅខ្ញុំទៅតាមគេទៅ ខ្ញុំទៅនឹងគេទៅ ជួបម៉ែក្មេកឪក្មេក ។

ធានី : ស្រុកគាត់នៅណាវិញ?

ស៊ានលី : ស្រុកនៅអង្គប្រាសាទ ។

ធានី : ចុះ! បានម៉េច មីងត្រឡប់មកដល់ភូមិនេះ?

ស៊ានលី : ដល់ហើយខ្ញុំអត់ចេះនៅស្រុកគេ ខ្ញុំមកវិញ ។

ធានី : ត្រឡប់មកនៅនេះ គាត់មកតាមមីង?

ស៊ានលី : គាត់មកតាមតើ ។

ធានី : កាលនឹងមីងស្ម័គ្រចិត្តចង់មានគ្រួសារខ្លួនឯង?

សាន់លី ៖ មានគ្រួសារខ្ញុំអត់ព្រមទេ!

ធានី ៖ គេបង្ខំ?

សាន់លី ៖ ចាស៎! គេបង្ខំ ព្រោះវ៉ៃខ្ញុំ ។

ធានី ៖ ដូចថាមីង តាមមើលធ្វើពេទ្យរហូតមកដល់ក្នុងស្រុកអីអញ្ចឹង ហើយមីងមានដែរឃើញហេតុការណ៍អីប្លែក ហើយមីងគិតថាខុសពីគោលរបស់អង្គការអីអញ្ចឹង មានដែរធ្លាប់មានទេ? មានដែរឃើញអីអញ្ចឹង ដឹងពុទេ?

សាន់លី ៖ ចាស៎! ធ្លាប់ឃើញ ។

ធានី ៖ មានអីទៀត?

សាន់លី ៖ យូរដែរអូនអើយ! ហើយខ្ញុំកាលនឹងនៅក្មេង លេងលេះល្អស់មិនសូវដឹងថាអ៊ីជាអ៊ីទេអូន ដូចថាយើងមិនយកចិត្តទុកដាក់ ។

ធានី ៖ អញ្ចឹង! មីងថាធ្លាប់ឃើញអញ្ចឹងមីង?

សាន់លី ៖ ចាស៎!

ធានី ៖ ឃើញអីគេទៅមីង?

សាន់លី ៖ ថាវ៉ារកនឹកមិនទាន់ឃើញ ។

ធានី ៖ ចុះ! ដូចថាមីងធ្វើពេទ្យអីអញ្ចឹង អង្គការគេមានប្រាប់ថាមានវិន័យម៉េច វិន័យអីៗខ្លះ?ដូចមិញ មីងនិយាយថា ប្រុសស្រីមិនឲ្យនិយាយគ្នាអីអញ្ចឹង ។ អញ្ចឹង! មានដែរធ្លាប់ឃើញមានផ្សេងគាត់ធ្លាប់មានអញ្ចឹងដែរអត់?

សាន់លី ៖ វិន័យគេដាក់ឲ្យយើងតឹងណាស់អូន គេថាយើងដើរផ្តោះផ្តាសអត់បាន យើងដើរជាមួយយុវជនក៏អត់បាន យើងនិយាយជាមួយយុវជនក៏អត់បានដែរ ។ ហើយទោះបី ខ្ញុំងូតទឹកខ្ញុំមិនដែរបានដោះអាវទេ ងូតទាំងអាវទាំងខោ ហើយតែយើងដោះអាវអីនឹង គេថាយើងបង្ហាញសាច់យុវជន ងាប់ទៀត ។

ធានី ៖ ធ្លាប់មានទេ មីង?

សាន់លី ៖ មាន ។

ធានី ៖ យើងចងពុម្ពធម្មតា ពេលងូតទឹក យើងនៅស្រុកនឹងយើងធ្លាប់ចងពុម្ពចងអី ។

សាន់លី ៖ ចាស៎! ហើយខ្ញុំនឹង មិនចងបានទេ គេថាខ្ញុំនឹងសអញ្ចឹង ចង់បង្ហាញសាច់យុវជន ។

លក្ខិណា ៖ មីងមានដែលតាមដានតុលាការកាត់ទោសមេខ្មែរក្រហមទេ?

សាន់លី ៖ អត់ដឹងអូន!

លក្ខិណា ៖ មីងដឹងថាមានតុលាការអីទេ?

ស៊ានលី ៖ អត់ដឹងខាងនោះទទេ ។

លក្ខិណា ៖ អត់ដែលស្តាប់វិទ្យុពូសួរ គេប្រកាសថាមានកាត់ទោសមេខ្មែរក្រហមអីមានទេមីង?

ស៊ានលី ៖ ពូសួរគេដែរអូនថា មានកាត់ទោសមេខ្មែរក្រហម ។

លក្ខិណា ៖ ពូសួរយូរនៅមីង?

ស៊ានលី ៖ ខ្ញុំពូសួរវិទ្យុនឹងនិយាយយូរដែរហើយ ។

លក្ខិណា ៖ ហើយមីងមានដែលតាមដានស្តាប់អីទេ?

ស៊ានលី ៖ ខ្ញុំមានតែអាកាភអូខេ ខ្ញុំអត់មានវិទ្យុខ្ញុំមានបើកស្តាប់ដែរ ។

លក្ខិណា ៖ ចុះ! មីងពូពីមុនកាត់ទោសនឹង មីងពូតាមពីណា?

ស៊ានលី ៖ ពូតាមវិទ្យុស្តាប់ផ្ទះគេអញ្ចឹងណាស់ ។

លក្ខិណា ៖ ពេលមីងស្តាប់តាមផ្ទះគេអញ្ចឹង មីងមានដឹងគេឃុំឃាំងអ្នកណាគេខ្លះទេមីង?

ស៊ានលី ៖ ពូថាគេកាត់អីអញ្ចឹង ខ្ញុំស្តាប់បានតែប៉ុននឹងទេ ។ ខ្ញុំក៏មកហូបបាយទៅ ខ្ញុំអត់មានតាមដាន ដឹងច្បាស់លាស់ទេអូន ។

លក្ខិណា ៖ មីងមានដែលពូគុកទួលស្លែងអីទេមីង?

ស៊ានលី ៖ ពូគេថា មិនដែលឃើញផង ។

លក្ខិណា ៖ ដែលទៅឃើញវា?

ស៊ានលី ៖ អត់ទេអូន មិនដែលទៅផង ។

លក្ខិណា ៖ ដឹងថានៅគុកទួលស្លែង កន្លែងនឹងធ្វើអីខ្លះទៅ?

ស៊ានលី ៖ មិនដឹងទេអូន ។

លក្ខិណា ៖ មីងមានដែលពូឈ្មោះ អៀង សារី នួន ជា ខៀវ សំផន អីទេមីង?

ស៊ានលី ៖ ខ្ញុំពូសួរឈ្មោះនឹង ខៀវ សំផន អៀង សារិ ពូយូរហើយ ។ ខ្ញុំពូសួរគេថា បាតុកម្ម ខៀវ សំផន នោះ ខ្ញុំពូសួរអញ្ចឹងដែរ ។

ធានី ៖ តាំងពីសម័យខ្មែរក្រហមយើង?

ស៊ានលី ៖ ចាស៎!

លក្ខិណា ៖ មីងមានដែរឃើញមុខគាត់អី?

ស៊ានលី ៖ អត់ទេអូន មិនដែលឃើញទេ ។

ធានី ៖ កាលនឹងម៉េចបានមីងដឹងគេ បាតុកម្មរឿង ខៀវ សំផន អី?

សាន់លី ៖ ទើបបាតុកម្ម គេបោកគេគុបនៅផ្សារអី ទើបដឹងអានឹងទេ ។

លក្ខិណា ៖ ប៉ុន្មានឆ្នាំហើយដែលមីងឮនឹង?

សាន់លី ៖ យូរដែរហើយអូន ។

ធានី ៖ មីងគិតថា តុលាការដែលបានពីស្ដាប់វិទ្យុរបស់មីង មីងគិតថាមានប្រយោជន៍ទេ ដែលបង្កើតវាមកនឹង? អានឹងចិត្តរបស់មីង ព្រោះមីងឮតាមអ្វីដែលមីងបានឮ យល់ថាម៉េចដែរ? ដូចថាមីងធ្លាប់ឆ្លងកាត់ផ្ទាល់ ហើយឥឡូវគេបង្កើតឲ្យមានការកាត់ទោសចំពោះមេដឹកនាំជាន់ខ្ពស់នៅសម័យខ្មែរក្រហមកាលសម័យនោះ ហើយចំពោះចិត្តមីងផ្ទាល់ មីងយល់ថាម៉េចដែរ?

សាន់លី ៖ អត់ល្អទេអូន ។

ធានី ៖ អត់ល្អយ៉ាងម៉េចមីង?

សាន់លី ៖ ចុះបើចាស់អញ្ចឹង កាត់សម្លាប់អញ្ចឹងល្អម៉េចអូន ។

ធានី ៖ អត់ល្អសម្រាប់គេ ឬក៏កាត់ទោសនឹងឥឡូវអត់ល្អ?

សាន់លី ៖ កាត់ទោសវាល្អ អាអត់កាត់វាអត់ល្អ ។

ធានី ៖ ម៉េចបានមីងយល់ថាកាត់ទោសនឹងវាល្អមីង?

សាន់លី ៖ ចុះបើយើងធ្វើខុសគេកាត់ទោសទៅ ។

ធានី ៖ អញ្ចឹង! មីងគិតថា តុលាការនឹងកាត់ទោសអញ្ចឹងល្អ អញ្ចឹង! អារម្មណ៍របស់មីងនឹង យល់ថា ល្អនឹងម៉េចដែរ ឬក៏វាយ៉ាងម៉េចសម្រាប់មីងផ្ទាល់?

សាន់លី ៖ វាមានប្រយោជន៍អូន ដូចថាកុំឲ្យអ្នកក្រោយយកគំរូតាម ។

ធានី ៖ កុំឲ្យគេយកគំរូតាម យើងខុសយើងត្រូវទទួលអញ្ចឹងមីង?

សាន់លី ៖ ចាស៎!

ធានី ៖ អញ្ចឹង! មីងគិតថា តុលាការនឹងមិនយុតិធម៌ ដូចថាអ្នកមិនមានកំហុស ប៉ុន្តែត្រូវទទួលកំហុសតែមីងប្រាប់ថា កាត់ទោសនឹងត្រូវតែធ្វើខុសទទួលកំហុស តើមានប្រយោជន៍សម្រាប់អ្នកដែលចាស់ៗដែលបានបាត់បង់ជីវិត តើមីងយល់ថាម៉េចដែរ? ដូចថាតើមានយុត្តិធម៌សម្រាប់មីងអត់ សម្រាប់ពួកគាត់អត់ ដែលឆ្លងកាត់សម័យនឹងដែរ? ដូចថាត្រូវគេបង្ខំឲ្យរៀបការដោយអត់ចង់ខ្លួនអីអញ្ចឹង ។ តើវាមានប្រយោជន៍ម៉េចអញ្ចឹង បើគេកាត់ទោស តើវាអាចផ្ដល់យុតិធម៌ អាល្អៗនឹងមកវិញដែរអត់?

សាន់លី ៖ អាយុតិធម៌ អយុតិធម៌នឹងវាខុសប្លែកគ្នាអូន ។

ធានី ៖ ខុសប្លែកគ្នាម៉េចមីង?

ស៊ានលី ៖ ខុសគ្នាដូចថា គេកាត់ទោសកាត់អីគេធ្វើត្រឹមទៅ អាខុសមិនដឹងខ្លួនខុសវាមិនត្រឹមត្រូវ ។

ធានី ៖ អញ្ចឹង! យើងព្យាយាមអ្នកដែលមិនដឹងខ្លួនខុសនឹងឲ្យត្រឹមត្រូវ ឲ្យគេដឹងវិញ?

ស៊ានលី ៖ ចាស៎!

ធានី ៖ មីងមានធ្លាប់និយាយរឿងប្រវត្តិរបស់មីងក្មេងៗជំនាន់ក្រោយអីទេ?

ស៊ានលី ៖ ខ្ញុំខស្សព្វាហ៍និយាយប្រាប់ក្មេងៗដែរ ។ ចុះ! សម័យឥឡូវចាយលុយច្រើន សម័យ ប៉ុល ពត ចាយលុយឯណា គ្មានចាយទេ ។ ដូចថា "ឯងគ្រប់គ្នា បើកើតជំនាន់ ប៉ុល ពត ងាប់អស់ហើយ ។

ធានី ៖ ប្រាប់អញ្ចឹងមីង?

ស៊ានលី ៖ ចាស៎!

ធានី ៖ កូនមីងថាម៉េចទៅ?

ស៊ានលី ៖ សើច វាអត់ដឹង

ធានី ៖ ហើយដល់អញ្ចឹងបានពួកខ្ញុំចុះមកអញ្ចឹង ក៏សុំសាកសួរមីង មីងក៏ប្រាប់ ។ ជួនកាល កូនមីងសួរអីអញ្ចឹង យូរៗប៉ះមួយ ។

ស៊ានលី ៖ ហើយចៅខ្ញុំ វាប្រាប់ថាចូលចិត្តបបរ "ឯងមិនចូលបបរ ដឹងងាប់ហើយកើតទាន់អាពត" ។

ធានី ៖ ហើយចៅថាម៉េចទៅមីង?

ស៊ានលី ៖ វាថា វាមិនដឹង ប៉ុល ពត អាម៉េចទេ ។

ធានី ៖ មីងខ្ញុំអស់សំនួរសួរមីងហើយ មីងមានអីចង់សួរពួកខ្ញុំវិញទេ?

លក្ខិណា ៖ មីងតុលាការនឹងផ្តល់យុត្តិធម៌ឲ្យយើងទេ?

ស៊ានលី ៖ ចាស៎! តុលាការគេកាត់ទោសអញ្ចឹង អាអ្នកត្រូវៗទៅ អាអ្នកខុសឲ្យដឹងខ្លួនខុសទៅ ។

លក្ខិណា ៖ ចុះ! ដូចថា តុលាការគេកាត់ទោសអត់ចប់អីអញ្ចឹង អ្នកដឹកនាំគាត់ចាស់ គាត់អីអញ្ចឹងគាត់ អាចស្លាប់មុនពេលគេកាត់ទោស គាត់ស្លាប់គេលែងកាត់ហើយ ។ តើតុលាការនឹងនៅតែរក យុត្តិធម៌ឲ្យមីងដដែរទេ?

ស៊ានលី ៖ អានឹងដូចថា រកអត់កើតទេ ព្រោះថាអ្នកនឹងស្លាប់ទៅហើយ ។

លក្ខិណា ៖ អញ្ចឹងបើតុលាការនឹងបរាជ័យអត់រកយុត្តិធម៌ជូនមីងបានទេ?

ស៊ានលី ៖ ចាស៎!

លក្ខិណា ៖ ចុះ! បើគេកាត់ទោសគាត់ដាក់គុកត្រឹម ៤០ ៣០ឆ្នាំ មីងគិតថាប៉ុននឹងសមចិត្តមីងទេ?

សុានលី ៖ ចាស៎! សមចិត្ត ។

ធានី ៖ អញ្ចឹង! មីងមានអីចង់បន្ថែមទៀត?

សុានលី ៖ អត់មានអីអូន ។

ធានី ៖ ទាក់ទងរឿងពួកខ្ញុំមកសួរ ។

សុានលី ៖ អត់មានអីសួរអូនឯង គ្រាន់និយាយអូនឯងៗកើតមិនទាន់ទេ ។ ដូចថា គេឲ្យអូនស្រលាញ់មីង គេឲ្យអូននេះអត់ស្រលាញ់អញ្ចឹង ឲ្យដឹងថាអញ្ចឹង គេបន្ទំៗគេវៃនឹងសុំយកកាំភ្លើង អត់ស្រលាញ់អញ្ចឹង ។

ធានី ៖ ចុះ! អ្នកស្រលាញ់មីង សុំនៅជាគ្នា...

សុានលី ៖ អត់បានទេ! ហើយកាលជំនាន់នឹងអូនអើយ អាណានឹងហើយមិនហ៊ានទៅសួរ ដឹងងាប់ហើយ ។ ម្នាក់នោះប្រុសស្អាត ស្រីអាក្រក់ កាលជំនាន់ ប៉ុល ពត ហើយអញ្ចឹងប្រុសនោះគេស្អាត គេអត់ព្រមជាមួយស្រីនឹង វាស្រីវាទៅប្រាប់អង្គការ អង្គការគេដាក់ស្នូកកាំភ្លើង ។ ហើយអាប្រុសនឹងអត់យកសោះ អត់យកអញ្ចឹង គេនឹងទៅប្រាប់ទៀតថា "អត់មានដេក អត់មានអោបរាវវាអីអញ្ចឹង" មកល្ងាចនឹងវៃទៀតហើយ ។

ធានី ៖ ហេតុអីមីង?

សុានលី ៖ គេឲ្យយក តែយើងមិនយកអានេះ ។ អាក្រក់គួរ អាសគួនឹងខ្មៅ ។

លក្ខិណា ៖ គេវៃមីងតែម្តង?

សុានលី ៖ ចាស៎! ហើយគេវៃអញ្ចឹង ឃើញអញ្ចឹង! ខ្លាចងាប់បានយក ប្តីខ្ញុំនឹងខ្មៅ មិនស្រលាញ់ ។ ឥឡូវអូនមិនដឹង ខ្ញុំប្រាប់ ។ ហើយសម័យនឹង តែមួយនឹងៗហើយអត់មានអាចទៅរកនោះបានទេ អត់ទេ ។

ធានី ៖ ហេតុអីទៅមីង?

សុានលី ៖ គេតឹងអញ្ចឹងអូន ។

ធានី ៖ តើធ្លាប់មានអ្នកដែលយើងអត់ពេញចិត្ត ហើយយើងចង់ទៅរកអ្នកផ្សេងអីអញ្ចឹងមានទេ? មីងមានដែលធ្លាប់ឃើញមានអញ្ចឹងទេមីង?

សុានលី ៖ ដូចថា មីងនិងអូនស្រលាញ់គ្នាអញ្ចឹង ដល់ពេលនេះគេឲ្យយកអានេះ ពេលនឹងយើងស្កាត់ជួបគ្នាក៏អត់បានដែរ ដឹងងាប់ហើយ ។

ធានី ៖ ដូចថាមានជាគំរូឲ្យយើងឃើញទេ?

សុានលី ៖ ឃើញ!

ធានី ៖ អ្នកណាគេមីង?

ស៊ានលី ៖ នៅជិតនាំជាមួយខ្ញុំ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ?

ស៊ានលី ៖ ខ្ញុំអត់ស្គាល់ទេ គេនៅស្រុកឆ្ងាយៗ ។

ធានី ៖ ហើយគាត់ធ្វើម៉េចទៅ?

ស៊ានលី ៖ គេឃើញ ។

ធានី ៖ គេឃើញគេថាម៉េច?

ស៊ានលី ៖ ដូចថា អ្នកនៅជាមួយគ្នាអញ្ចឹង គេឃើញអញ្ចឹងថាយើងស្រលាញ់គ្នា ដល់ហើយទៅជាមួយប្តីនេះ អត់សោះស្រលាញ់ទេ ។ យើងមកជួបជាមួយនេះ ហើយអ្នកនេះឃើញប្រាប់អន្តការ ។

ធានី ៖ អញ្ចឹងពីរនាក់នឹងគេយកទៅណាទៅ?

ស៊ានលី ៖ ពីរនាក់នឹងគេវៃម្ខាងចោល ទុកម្ខាងទៅ ។ គេវៃខាងយើងស្រលាញ់ចោលម្ខាង ទុកអានឹងវានៅជាមួយគ្នាទៅ វាស្រលាញ់គេហើយ ។

ធានី ៖ ចុះ! ដល់វៃខាងណា?

ស៊ានលី ៖ គេវៃខាងស្រីទៅ ខាងប្រុសហើយអានឹងឲ្យជួបគ្នាទៅ ។

ធានី ៖ ខាងប្រុសនឹង អ្នកណាគេមីង?

ស៊ានលី ៖ ដូចថា ខ្ញុំប្តីអញ្ចឹង ដល់ហើយខ្ញុំស្រលាញ់ប្អូនឯង ប្អូនឯងស្រលាញ់ខ្ញុំអញ្ចឹង ។ ដល់ពេលហើយ យើងបែកពីអានេះហើយ មកជួបអានេះភ្លេតអត់បានទេ ។

ធានី ៖ ហើយម៉េចបានគេយកតែខាងស្រីទៅ?

ស៊ានលី ៖ ចុះ! បើថា ទុកស្រីនឹងទៅ អានឹងវាចេះមករកជួបគ្នា ។

ធានី ៖ ម្នាក់ស្រីនឹងអត់ទាន់មានគ្រួសារ ឬក៏មេច?

ស៊ានលី ៖ ម្នាក់ស្រីនឹងអត់ទាន់មានគ្រួសារទេ ។

ធានី ៖ ចុះ! មានដែរធ្លាប់មានទេ? ដូចថា ដូរគូគ្នាអីអញ្ចឹង មានទេមីង?

ស៊ានលី ៖ អត់មានទេអូន គូណាគូនឹងហើយ ។ ឮខ្ញុំនិយាយ ម៉ាខែ្សរោងវែង អូនឯងឲ្យក្រមាមកខ្ញុំហើយខ្ញុំឲ្យក្រមាអូនឯង អញ្ចឹងចំណាំតែក្រមាទេណា ។

ធានី ៖ ចុះ! ឲ្យគ្នាអត់មើលមុខគ្នាឃើញទេ?

ស៊ានលី ៖ មើលគ្នា តែមិនសូវច្បាស់យប់ មើលតែក្រមាទេ ។

លក្ខិណា ៖ មានអ្នកប្រឡុំក្រមាទេ?

ស៊ានលី ៖ មានអ្នកប្រឡុំក្រមា ។ អ្នកប្រឡុំក្រមាដល់ហើយ បានស្គាល់គ្នាវិញ ដូរគ្នាវិញទៅ ។ អូន អើយ! ពិបាកមាំណាស់ ។

ធានី ៖ មីងមានអីត្រូវថែមទៀតទេមីង?

ស៊ានលី ៖ មានអីទេអូន ។

ធានី ៖ ចាស៎! អញ្ជើញអរគុណច្រើនមីង ។

«ចប់»